**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences economicus
Royal university of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍឃុំ-សង្កាត់

## (ករណីសិក្សាៈ សង្កាត់បឹងត្របែក)

ស្រាវជ្រាវចាប់ពីថ្ងៃទី ០៨ ខែ មេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០២៤

តាក់តែងឡើងដោយ
និស្សិតឈ្មោះ: **កញ្ញា យុន ស្រីនីន**
**កញ្ញា សាឡៃ សុគន្ធា**

ណែនាំដោយ
សាស្ត្រាចារ្យជំនួយ **ខួន ហេង**

ថ្នាក់បរិញ្ញាបត្រ **សេដ្ឋកិច្ចអភិវឌ្ឍន៍**
ជំនាន់ទី ០៨

ឆ្នាំចូលសិក្សា ២០២០
ឆ្នាំសសេរសារណា ២០២៤

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences economicus

Royal university of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍឃុំ-សង្កាត់

## (ករណីសិក្សា៖ សង្កាត់បឹងត្របែក)

ស្រាវជ្រាវចាប់ពីថ្ងៃទី ០៨ ខែ មេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០២៤

តាក់តែងឡើងដោយ

និស្សិតឈ្មោះ៖ **កញ្ញា ឃុន ស្រីនីន**

**កញ្ញា សាឡៃ សុគន្ធា**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **ខួន ហេង**

ថ្នាក់បរិញ្ញាបត្រ **សេដ្ឋកិច្ចអភិវឌ្ឍន៍**

ជំនាន់ទី ០៨

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **យុន ស្រីនីន** និង **សាឡៃ សុគន្ធា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ឆ្នាំទី៤ ជំនាន់ទី០៨ ក្រុមD4A1កំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានសិក្សាស្រាវជ្រាវនៅសង្កាត់បឹងត្របែកបានបញ្ចប់ទៅលើប្រធានបទ **ការអភិវឌ្ឍសង្កាត់បឹងត្របែក** ដោយមានការជ្រោមជ្រែងពីសំណាក់មជ្ឈដ្ឋានជាច្រើន។ អាស្រ័យហេតុនេះក្រុមយើងខ្ញុំសូមសម្តែងនូវកតញ្ញូធម៌និងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

លោកឪពុក អ្នកម្តាយ ដែលជាអ្នកមានគុណទាំងពីរដែលបានផ្តល់កំណើត និងខិតខំជំនះរាល់បញ្ហាទាំងឡាយក្នុងការចិញ្ចឹមបីបាច់ថែរក្សាប្រៀនប្រដៅ ព្រមទាំងផ្គត់ផ្គង់ឧបត្ថម្ភគ្រប់បែបយ៉ាងទាំងស្មារតី និងថវិកាដល់ពួកយើងទាំងពីររហូតទទួលបានការសិក្សា និងបានអប់រំទូន្មានប្រៀនប្រដៅយ៉ាងយកចិត្តទុកដាក់ទំនុកបំរុង និងផ្តល់ភាពកក់ក្តៅសព្វបែបយ៉ាងដល់រូបកូនផ្តល់កម្លាំងចិត្ត និងបានជម្រុញឱ្យកូនបានសិក្សាខ្ពង់ខ្ពស់ដើម្បីឱ្យកូនក្លាយជាពលរដ្ឋល្អនៅក្នុងសង្គម។

ឯកឧត្តមបណ្ឌិត លុយ ចណ្ណា សាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកលោកស្រីសាស្ត្រាចារ្យសាស្ត្រាចារ្យរងសាស្ត្រចារ្យជំនួយលោកគ្រូ អ្នកគ្រូគ្រប់មហាវិទ្យាល័យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានខិតខំប្រឹងប្រែងទាំងកម្លាំងកាយ និងកម្លាំងចិត្តក្នុងការបង្ហាត់បង្រៀនណែនាំ ចង្អុលបង្ហាញ និងផ្តល់ជាចំណេះដឹងជួយពង្រឹងទាំងផ្នែកប្រាជ្ញាស្មារតីគ្រប់បែបយ៉ាងអស់រយៈពេលបួនឆ្នាំ កន្លងមកព្រមទាំងជួយផ្តល់ជាឯកសារផ្សេងៗដល់ពួកយើងខ្ញុំក្នុងការពង្រឹងចំណេះដឹង។

លោកសាស្ត្រាចារ្យជំនួយ ងួន ហេង ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំចង្អុលបង្ហាញតម្រង់ទិសផ្តល់យោបល់និងដំបូន្មានល្អៗដើម្បីជួយសម្រួលដល់ការសរសេរនូវរបាយការណ៍សារណាបញ្ចប់ ការសិក្សា និងជួយកែលម្អនូវចំណុចខ្វះខាតទោះបីមានភាពមមាញឹកក្នុងការបំពេញតួនាទីការងារ និងភារកិច្ច យ៉ាងណាក្តី។

សូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតថែមទៀតចំពោះអ្នកនិពន្ធ និងអ្នកប្រាជ្ញព្រមទាំងទស្សនៈវិទូល្បីៗក្នុងលោកដែលយើងខ្ញុំបានសិក្សាស្រាវជ្រាវពីស្នាដៃរបស់លោកក្នុងការបំពេញកិច្ចការស្រាវជ្រាវនៅពេលកន្លងមក។សូមមេត្តាទទួលនូវអំណរគុណដ៏ជ្រាលជ្រៅបំផុតដ៏ធំធេងអំពីយើងខ្ញុំ និងមិនអាចបំភ្លេចបានចំពោះឧបការគុណ។

ជាទីបញ្ចប់នេះ យើងខ្ញុំសូមប្រសិទ្ធពរជ័យសិរីបវរជូនដល់ លោកអ្នកមានគុណ ឯកឧត្តម លោកជំទាវ លោកលោកស្រី និងសាស្ត្រាចារ្យទាំងអស់ សូមបានប្រកបតែជោគជ័យគ្រប់ភារកិច្ច និងសូមទទួលបាននូវពុទ្ធពរទាំងបួន ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

ក្រោយពីបានបញ្ចប់ការសិក្សាទៅលើទ្រឹស្តីនៃ មុខវិជ្ជាសេដ្ឋកិច្ចអភិវឌ្ឍន៍អស់រយៈពេលជិតបួនឆ្នាំមកនេះ យើងខ្ញុំទាំងពីរបានទទួលនូវចំណេះដឹងជាច្រើនទាំងផ្នែកទ្រឹស្តីនិង ការអនុវត្តនៅក្នុងផ្នែកនេះ។ស្ថិតនៅក្នុងដំណាក់កាលឆ្នាំទី៤របស់យើងខ្ញុំទាំងពីរ រូបដោយផ្អែកតាមលទ្ធភាពចំណេះដឹងនៃការសិក្សាទាំងអស់នេះហើយជាកត្តាយ៉ាង សំខាន់ដែលជម្រុញឱ្យខ្ញុំទាំងពីររូបមានឱកាសក៏ដូចជាលទ្ធភាពដែលអាចសរសេរសារណាបញ្ចប់ការសិក្សាមួយទុកសម្រាប់ជាឯកសារ ជំនួយស្មារតីដល់និស្សិតសិស្សប្អូនជំនាន់ក្រោយ។ ហើយការចងក្រងសារណា បញ្ចប់ការសិក្សាមួយនេះជាឱកាសដ៏ល្អមួយដែលអាចវាស់ស្ទង់បន្ថែមនូវចំណេះដឹងរបស់យើងខ្ញុំទាំងពីររូបដែលមានពីមុនមកនិងការធ្វើការសិក្សាស្រាវជ្រាវបន្ថែម។ បរិបទបែបនេះហើយដែលជាហេតុបណ្តាលអោយខ្ញុំទាំងពីរនាក់បានជ្រើសរើសយកប្រធានបទមួយដែលស្តីពី**ការអភិវឌ្ឍឃុំ-សង្កាត់**( **ករណីសិក្សាៈ សង្កាត់បឹងត្របែក** )មកធ្វើជាប្រធានបទក្នុងការសរសេរសារណាបញ្ចប់ការសិក្សា។

មុននឹងបញ្ចប់នាងខ្ញុំទាំងពីរនាក់សូមគោរពទទួលយកនូវរាល់កំហុសខុសឆ្គងណាមួយដោយចេតនាក្តី ដោយអចេតនាក្តីឬនៅមានភាពខ្វះខាតចន្លោះត្រង់កន្លែងណាមួយសូមមេត្តា ខន្តីអភ័យទោសប្រកបដោយសេចក្តីគោរពដល់ខ្ពង់ខ្ពស់បំផុតពីសំណាក់នាងខ្ញុំ ទាំងពីររូបហើយយើងខ្ញុំទាំងពីររូបនឹងទទួលរង់ចាំនូវរាល់មតិរិះគន់កែលម្អនូវរាល់ចំណុះខ្វះខាតទាំងឡាយក្នុងន័យស្ថាបនាដើម្បីឱ្យការស្រាវជ្រាវមួយនេះមានន័យគ្រប់គ្រាន់បន្ថែមទៀត។

ជាទីបញ្ចប់នាងខ្ញុំទាំងពីរ សូមគោរពជូនពរដល់ មិត្តនិស្សិត មិត្តអ្នកអានទាំងអស់គ្នា ឱ្យទទួលបាននូវភាពជោគជ័យគ្រប់ភារកិច្ច និងមានកម្លាំងពលមាំមួនខ្លាំងក្លាប្រាជ្ញាវាងវៃមានអាយុយឺនយូរជៀសផុតពីជំងឺទាំងឡាយទាំងពួង រកទទួលទានមានបានគ្រប់គ្នា ព្រមទាំងជួបនូវពុទ្ធពរទាំង បួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ


បញ្ជីអក្សរកាត់ ........ vi

បញ្ជីតារាង ........ vii

បញ្ជីក្រាហ្វិក ........ viii

បញ្ជីឧបសម្ព័ន្ធ ........ ix


## សេចក្តីផ្តើម


១. លំនាំបញ្ហា ........ ១

២. ចំណោទបញ្ហា ........ ១

៣. គោលបំណងក្នុងការសិក្សាស្រាវជ្រាវ ........ ២

៤. វិសាលភាពនិងដែនកំណត់នៃការស្រាវជ្រាវ ........ ២

៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ........ ២

៦. វិធីសាស្រ្តក្នុងការសិក្សាស្រាវជ្រាវ ........ ៣

៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ ........ ៣


## ជំពូកទី១

## រំលឹកទ្រឹស្តី ដែលពាក់ព័ន្ធ


**១.១. និយមន័យទូទៅនៃសេដ្ឋកិច្ចអភិវឌ្ឍន៍ ........ ៤**

១.១.១. និយមន័យអភិវឌ្ឍន៍ ........ ៤

១.២.១ គោលបំណងនៅក្នុងការអភិវឌ្ឍ ........ ៥

**១.២.ទ្រឹស្តីនៃការអភិវឌ្ឍរបស់អ្នកសេដ្ឋកិច្ចវិទូ ........ ៧**

១.២.១.ទ្រឹស្តីកំណើនលោក Walt Withman Roston ........ ៧

១.២.២.ទ្រឹស្តីAnglo-Saxon ........ ៩
១.២.៣.ទ្រឹស្តី Lewis ........ ៩
១.២.៤.ទ្រឹស្តី Michael P.Todaro ........ ១០
១.២.៥.ទ្រឹស្តី Solow ........ ១០
**១.៣.កត្តាជម្រុញដល់ការអភិវឌ្ឍសេដ្ឋកិច្ច** ........ ១១
១.៣.១.ធនធានមនុស្ស ........ ១២
១.៣.២.ធនធានមូលធន ........ ១៣
១.៣.៣.ធនធានធម្មជាតិ ........ ១៣
១.៣.៤ ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ........ ១៤
១.៣.៥ ការអភិវឌ្ឍតាមបែបចូលរួម ........ ១៥
ក. និយមន័យនៃការចូលរួម ........ ១៥
ខ. កម្រិតនៃការចូលរួម ........ ១៥
គ. គោលការណ៍នៃការអភិវឌ្ឍតាមបែបចូលរួម ........ ១៦

## ជំពូកទី២

## ស្ថានភាពទូទៅ និងរចនាសម្ព័ន្ធការគ្រប់គ្រងក្នុងសង្កាត់បឹងត្របែក

**២.១ ទិដ្ឋភាពទូទៅនៅក្នុងសង្កាត់បឹងត្របែក** ........ ១៧
២.១.១.ស្ថានភាពភូមិសាស្រ្ត ........ ១៧
**២.២ រចនាសម្ព័ន្ធនិងការគ្រប់គ្រងរដ្ឋបាលសង្កាត់បឹងត្របែក** ........ ១៧
២.២.១.មេឃុំ ចៅសង្កាត់ ........ ១៨
២.២.២.ជំទប់ ចៅសង្កាត់រង ........ ១៨
២.២.៣.ស្មៀន ........ ១៨
២.២.៤.មេភូមិ ........ ១៨
**២.៣. ស្ថានភាពទូទៅ** ........ ១៩
ក. ឃុំ សង្កាត់ និងការអភិវឌ្ឍ ........ ១៩

ខ. វិមជ្ឈការ និងប្រសិទ្ធភាព ........ ១៩
គ. អភិបាលឃុំ សង្កាត់ ........ ២០
២.៣.១សមាសភាពក្រុមប្រឹក្សាសង្កាត់បឹងត្របែក ........ ២១
២.៣.២ តួនាទីរបស់ក្រុមប្រឹក្សាសង្កាត់ ........ ២១
២.៣.៣ តួនាទីជាអ្នកតំណាងអោយ ប្រជាពលរដ្ឋ ........ ២២
២.៣.៤ តួនាទីជាអ្នកតំណាងអោយរដ្ឋ ........ ២២
**២.៤ អភិបាលកិច្ចល្អ គណនេយ្យភាព** ........ ២២
២.៤.១.អភិបាលកិច្ចល្អ ........ ២២
២.៤.២ គណនេយ្យភាព ........ ២៣
ក. គណនេយ្យភាពចំពោះប្រជាពលរដ្ឋ ........ ២៣
ខ. គណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ........ ២៣
២.៤.៣ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់សង្កាត់ ........ ២៣
២.៤.៤.ប្រភពចំណូលសំខាន់ៗរបស់សង្កាត់ ........ ២៤
២.៤.៥. ការរៀបចំថវិកា ........ ២៥
២.៤.៦. ការអនុវត្តថវិការឃុំ សង្កាត់ ........ ២៥
២.៤.៧. ការចូលរួមរបស់ប្រជាពលរដ្ឋ ........ ២៦
**២.៥ ក្រុមប្រឹក្សាសង្កាត់** ........ ២៧
២.៥.១.គណៈកម្មាធិការកសាងផែនការនិងថវិកា ........ ២៨
២.៥.២.គណៈកម្មាធិការគ្រប់គ្រងគម្រោង ........ ២៨
២.៥.៣.ការកសាងផែនការនៃការអភិវឌ្ឍឃុំ-សង្កាត់ ........ ២៩
ក. ការរៀបចំយន្តការ ........ ២៩
ខ.ដំណើរការកសាងផែនការឃុំ សង្កាត់ ........ ៣០
គ. ការអនុវត្តន៍ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ........ ៣១
ឃ.ការតាមដាន និងវាយតម្លៃលើផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ........ ៣១
ង.ការឆ្លើយតបរបស់ផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ........ ៣២

## ជំពូកទី៣
## ស្ថានភាពទូទៅជុំវិញការអភិវឌ្ឍក្នុងសង្កាត់បឹងត្របែក

**៣.១. ស្ថានភាពអភិវឌ្ឍក្នុងសង្កាត់បឹងត្របែក** .......... ៣៣
៣.១.១. ស្ថានភាពសេដ្ឋកិច្ច .......... ៣៣
ក. អាជីវកម្ម .......... ៣៣
ខ. ការងារទេសចរណ៍ .......... ៣៣
គ. ការងារសាធារណការ .......... ៣៣
ឃ. ការងារកសិកម្ម .......... ៣៤
៣.១.២.ស្ថានភាពសង្គមកិច្ច .......... ៣៤
ក. ការងារអប់រំ .......... ៣៤
ខ. សុខាភិបាល .......... ៣៤
គ. ការងារវប្បធម៌ និងសាសនា .......... ៣៤
ឃ. ការងារយេនឌ័រ .......... ៣៥
៣.១.៣. ស្ថានភាពនៃការគ្រប់គ្រងធនធានធម្មជាតិ .......... ៣៥
៣.១.៤. ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាលនិងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ .......... ៣៥
ក. ការគ្រប់គ្រងដែនដី .......... ៣៥
ខ. ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ .......... ៣៦
**៣.២. ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងឆ្នាំ២០១៨-២០២២**
៣.២.១. ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងឆ្នាំ២០១៨ .......... ៣៦
៣.២.២. ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងឆ្នាំ២០១៩ .......... ៣៧
៣.២.៣. ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងឆ្នាំ២០២០ .......... ៣៧
៣.២.៤. ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងឆ្នាំ២០២១ .......... ៣៨
៣.២.៥. ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងឆ្នាំ២០២២ .......... ៣៩

## ជំពូកទី៤
## ការវិភាគទិន្នន័យនៃការអភិវឌ្ឍផ្លូវនិងប្រព័ន្ធលូដែលសង្កាត់បឹងត្របែកបានជួសជុលពីឆ្នាំ២០១៨ដល់២០២២

**៤.១.ទិន្នន័យផ្លូវដែលសង្កាត់បឹងត្របែកបានជួសជុលពីឆ្នាំ២០១៨-២០២២**

៤.១.១.តារាងទិន្នន័យផ្លូវចាក់កៅស៊ូដែលបានជួសជុលឆ្នាំ២០១៨-២០២២..................៤១

៤.១.២.ក្រាហ្វិកផ្លូវចាក់កៅស៊ូដែលជួសជុលបានឆ្នាំ២០១៨-២០២២......................... ៤២

៤.១.៣.ការវិភាគនិងបកស្រាយទិន្នន័យផ្លូវជួសជុលចាក់កៅស៊ូតាមក្រាហ្វិកដែលសង្កាត់បឹងត្របែកពីឆ្នាំ២០១៨-២០២២ ................................................................... ៤២

**៤.២.ទិន្នន័យលូដែលសង្កាត់បឹងត្របែកបានជួសជុលពីឆ្នាំ២០១៨-២០២២**

៤.២.១.តារាងទិន្នន័យលូដែលបានជួសជុលឆ្នាំ២០១៨-២០២២.............................. ៤៣

៤.២.២.ក្រាហ្វិកលូដែលសម្រេចបានជួសជុលឆ្នាំ២០១៨-២០២២ ........................... ៤៤

៤.២.៣.ការវិភាគនិងបកស្រាយទិន្នន័យលូតាមក្រាហ្វិកដែលសង្កាត់បានជួសជុលពីឆ្នាំ២០១៨-២០២២ ....................................................................... ៤៥

**៤.៣.បញ្ហាប្រឈមនៃការអភិវឌ្ឍនិងដំណោះស្រាយ**...................................៤៥

៤.៣.១.ហេដ្ឋារចនាសម្ព័ន្ធ ..........................................................................៤៥

៤.៣.២.អាជីវកម្ម .....................................................................................៤៦

**៤.៤.ចំណុចខ្លាំងចំណុចខ្សោយ**...........................................................................៤៦

**១. សេចក្តីសន្និដ្ឋាន** ..................................................................................៤៨

**២. ការផ្តល់អនុសាសន៍**....................................................................................៤៩

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

គ.ក.ន.ក : គណនៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ

គ.ជ.អ.ប : គណនៈកម្មាធិការជាតិសម្រាប់ការ អភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

គ.ផ.ថ. : គណៈកម្មាធិការកសាងផែនការ និងថវិកា ។

UNDP : កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិដែលមានពាក្យពេញ (United Nations Development Programme) មានឈ្មោះហៅកាត់ថា យូអឹនឌីភី(UNDP) គឺជាទីភ្នាក់ងារបណ្ដាញអភិវឌ្ឍន៍សកលលោករបស់អង្គការសហប្រជាជាតិ ។

# បញ្ជីតារាង

តារាងទី ៤.១.១៖ ផ្លូលេខនិងប្រវែងជួសជុលផ្លូវអ៊ុតកៅស៊ូ
តារាងទី ៤.១.៣៖ តារាងផ្លូវលេខនិងប្រវែងដែលបានជួសជុលដាក់លូ

# បញ្ជីក្រាហ្វិក

ក្រាហ្វិកទី៤.១.២៖ ការសម្រេចបានក្នុងការជួសជុលចាក់អ៊ុតកៅស៊ូAC(២០១៨-២០២២)
ក្រាហ្វិកទី៤.១.៤៖ ក្រាហ្វិកលូដែលសម្រេចបាន(២០១៨-២០២២)

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ៖ ផែនទីសង្កាត់បឹងត្របែក
ឧបសម្ព័ន្ធទី២ ៖ រូបភាពសាលាសង្កាត់បឹងត្របែក
ឧបសម្ព័ន្ធទី៣ ៖រចនាសម្ព័ន្ធការគ្រប់គ្រងឃុំ សង្កាត និងរូបភាពការរៀបចំជួសជុលផ្លូវនិងជួសជុលលូ
ឧបសម្ព័ន្ធទី៤ ៖របាយការណ៍លទ្ធផលសម្រេចបានក្នុងការជួសជុលផ្លូវអ៊ុតកៅស៊ូACឆ្នាំ២០១៨-២០២២របស់សង្កាត់បឹងត្របែក)។

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ

ប្រទេសកម្ពុជា បន្ទាប់ពីឆ្លងកាត់ស្បែអន្តការយ៉ាងខ្មៅងងឹតអស់រយៈពេលជាច្រើនឆ្នាំកន្លងដែលធ្វើឱ្យ មានការខូចខាតផ្នែក ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ក៏បានប្រែមុខមាត់ថ្មី ដោយមានការរីកចម្រើន និងអភិវឌ្ឍន៍ជាលំដាប់គួរឱ្យកត់សម្គាល់នៅរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ចាប់ផ្តើមពីចំនុចសូន្យរហូតដល់មានការអភិវឌ្ឍដូចសព្វថ្ងៃនេះ ដោយអនុវត្តនូវគោលនយោបាយ ឈ្នះ-ឈ្នះ របស់ប្រមុខរាជរដ្ឋាភិបាល និងមានការចូលរួមយ៉ាង សកម្មពីសំណាក់ប្រជាពលរដ្ឋទូទាំងប្រទេស យើងសង្កេតឱ្យឃើញថាប្រទេសកម្ពុជា កំពុងតែមានការអភិវឌ្ឍ រីកចម្រើនគ្រប់វិស័យមិនថាវិស័យរដ្ឋ ឬឯកជន។ ទន្ទឹមនឹងនេះផងដែររាជរដ្ឋាភិបាលកម្ពុជាតែងតែផ្តោតទៅលើ ការលើកទឹកចិត្តយ៉ាងខ្លាំង ដល់ប្រជាពលរដ្ឋឱ្យមានការអភិវឌ្ឍបែបប្រជាធិបតេយ្យស្របពេលដែលនយោបាយ មានស្ថេរភាព និងរចនាសម្ព័ន្ធតាមបែបប្រជាធិបតេយ្យត្រូវបានពង្រឹងទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បី ធានាដល់ការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព ក្នុងនោះផងដែររាជរដ្ឋាភិបាលថ្នាក់ក្រោមជាតិត្រូវបាន បង្កើតឡើងនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

ក្នុងពេលដែលប្រទេសកម្ពុជា ស្ថិតនៅក្នុងប្រទេសអភិវឌ្ឍន៍ ដោយរាជរដ្ឋាភិបាលកំពុងធ្វើកំណែទម្រង់ ទៅលើគ្រប់វិស័យ ជាពិសេសនៅក្នុងការអភិវឌ្ឍនានាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ដែលការអភិវឌ្ឍ គឺជាកូនសោរដ៏សំខាន់មួយក្នុងចំណោមកូនសោរដទៃទៀតដើម្បីប្រទេសជាតិមានការរីកចម្រើន។ដោយសារ ឃើញពីមានការរីកចម្រើននៃការអភិវឌ្ឍរបស់សង្កាត់ ទើបក្រុមនាងខ្ញុំបានលើកយកប្រធានបទដែលស្តីអំពី ការអភិវឌ្ឍសង្កាត់បឹងត្របែក ហើយសង្កាត់នេះផងដែលជាតំបន់ដែលមានការអភិវឌ្ឍល្អ និងមានការរីកចម្រើនមួយក្នុងចំណោមសង្កាត់ផ្សេងៗទៀតក្នុងខណ្ឌចំការមនផងដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីជាស្ពានឈានដល់ ការបកស្រាយលើប្រធានបទខាងលើឱ្យបានស៊ីជម្រៅ ក៏ដូចជាឱ្យមានភាពច្បាស់លាស់បន្ថែមទៀតនោះយើងខ្ញុំទាំងពីររូបបានលើកយកចំណោទបញ្ហាមួយចំនួនមកធ្វើការបកស្រាយដែលបញ្ហាទាំងអស់នោះរួមមានៈតើសាលាសង្កាត់បឹងត្របែកមានរចនាសម្ព័ន្ធគ្រប់គ្រងដូចម្តេចខ្លះ?តើសាលាសង្កាត់បឹងត្របែកបានអភិវឌ្ឍនិងសម្រេចបានលទ្ធផលអ្វីខ្លះនៅក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ(២០១៨-២០២២)?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ក្នុងគោលបំណងកំណត់យកប្រធានបទទាក់ទងទៅនឹងការអភិវឌ្ឍសង្កាត់បឹងត្របែកយកសរសេរជាប្រធានបទសម្រាប់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកសេដ្ឋកិច្ចអភិវឌ្ឍន៍ នេះគឺមានគោលបំណងចង់បង្ហាញអំពីការអភិវឌ្ឍរបស់សង្កាត់បឹងត្របែកនាពេលបច្ចុប្បន្ននេះដែលធ្វើឱ្យមានការរីចម្រើន ជឿនលឿនពីព្រោះថានា

ពេលបច្ចុប្បន្ន ការអភិវឌ្ឍសង្កាត់បឹងត្របែក គឺមានការវិនិយោគជាច្រើនក្នុងនោះផងដែរ មិនថាហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ប្រព័ន្ធលូ លំនៅដ្ឋាន សាលារៀន និងកន្លែងនានា សុទ្ធតែទៅតាមស្តង់ដារ ដើម្បីបម្រើដល់ប្រជាជន នៅក្នុងតំបន់មួយនេះឱ្យមានការរស់នៅកាន់តែប្រសើរឡើង។ ជាងនេះទៅទៀត គោលបំណងនៃការបង្កើតនូវស្នាដៃនៃការសិក្សាស្រាវជ្រាវលើប្រធានសារណាមួយ នេះឡើង គឺមាននូវគោលបំណងក្នុង ការបង្ហាញអំពីការអភិវឌ្ឍរបស់សង្កាត់បឹងត្របែក ទៅតាម គោលនយោបាយ គោលការណ៍ ប្រែក្លាយទៅជាសង្កាត់ មួយ ដែលប្រកបដោយគុណភាពក្នុងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

## ៤. វិសាលភាពនិងដែនកំណត់នៃការស្រាវជ្រាវ

នៅតាមសង្កាត់នីមួយៗនៅក្នុងប្រទេសកម្ពុជាតែងតែលើឡើងនៅការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជារៀងរាល់ឆ្នាំ ក្នុងនោះសង្កាត់បឹងត្របែក បានបង្ហាញនូវសកម្មភាពគោលការណ៍ គម្រោងការងារ និងកម្មវិធីមូលនិធិក្នុងសង្កាត់ដែលមានការចូលរួមពីប្រជាជនក្នុងមូលដ្ឋានប៉ុន្តែក្រុមយើងខ្ញុំក្នុងសារណានេះយើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវទៅលើការអភិវឌ្ឍសង្កាតើបឹងត្របែកតែទីលើការជួសជុលផ្លូវថ្នល់និងប្រព័ន្ធលូពីឆ្នាំមាននៅក្នុងសង្កាត់បឹងត្របែក ចាប់ពីឆ្នាំ២០១៨ដល់២០២២តែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវទៅលើអត្ថបទសារណាមួយនេះ គឺមានគោលបំណងសំខាន់ដើម្បីផ្តល់សារៈប្រយោជន៍ដល់មិត្តនិស្សិត មិត្តអ្នកអាន មិត្តអ្នកស្រាវជ្រាវ ទាំងអស់ឱ្យបានយល់ដឹងឱ្យ កាន់តែច្បាស់ និងស៊ីជម្រៅអំពីការអភិវឌ្ឍរបស់សង្កាត់បឹងត្របែក ជាមួយនឹងការអភិវឌ្ឍលើវិស័យផ្សេងៗ ដូចជាហេដ្ឋារចនាសម្ព័ន្ធទាំងអស់ដែលអាចធ្វើឱ្យសង្កាត់បឹងត្របែក មានការរីកចម្រើនល្អ។ មិនត្រឹមតែប៉ុណ្ណោះ អត្ថបទសារណាមួយនេះក៏បានចូលរួមចំណែកក្នុងការបង្ហាញ នៃការជម្រុញឱ្យមាននូវ ការអភិវឌ្ឍថ្មីៗ បន្ថែមទៀតផងដែរ។

- **ចំពោះក្រុមសិក្សាស្រាវជ្រាវរបស់យើងខ្ញុំ**

- ផ្សារភ្ជាប់ទ្រឹស្តីដែលបានសិក្សាកន្លងមកទៅនិងការអនុវត្តជាក់ស្តែងឬការអនុវត្តដោយផ្ទាល់
- បង្កើនចំណេះដឹងបន្ថែមពីការអភិវឌ្ឍជាពិសេសផ្នែក ផ្លូវថ្នល់ និង ប្រព័ន្ធលូ
- ទុកជាឯកសារដល់អ្នកដែលចូលចិត្តអានដែលទាក់ទងនិងការអភិវឌ្ឍ និងទាក់ទងនិងការកសាងហេដ្ឋារចនាសម្ព័ន្ធ
- ទទួលបាននូវបទពិសោធន៍ល្អៗដែលទាក់ទងនិងមុខជំនាញដែលយើងកំពុងសិក្សាដើម្បីយកទៅអនុវត្តន៍ពេលអនាគត។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវអាចសម្រេចទៅបាន លុះត្រាតែយើងអាចប្រមូលបានទិន្នន័យចាំបាច់ ដែលទាក់ទងទៅនឹងដំណើរការអភិវឌ្ឍ។ ដើម្បីទទួលបាននូវទិន្នន័យទាំងនេះនៅក្នុងការសិក្សាស្រាវជ្រាវរបស់ពួកយើងខ្ញុំបានប្រើប្រាស់ វិធីសាស្ត្រដែលបានអនុវត្តន៍ទៅតាមដំណាក់កាលបន្តបន្ទាប់ដូចខាងក្រោម៖

**ទិន្នន័យចំបង** គឺជាទិន្នន័យដែលយើងទទួលបានពីការសម្ភាស៍ផ្ទាល់ជាមួយនិងលោកចៅសង្កាត់បឹងត្របែករួមទាំងសម្ភាស៍ផ្ទាល់ជាមួយភាគីដែលពាក់ព័ន្ធ។

**ទិន្នន័យបន្ទាប់បន្សំ** គឺជាទិន្នន័យដែលមានស្រាប់ប្រមូលតាមសៀវភៅទ្រឹស្តីអ្នកសេដ្ឋកិច្ចល្បីៗពីបណ្ណាល័យ Websitនិងសៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរបស់សង្កាត់បឹងត្របែករួមទាំងរបាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តន៍កម្មវិធីនយោបាយអភិវឌ្ឍន៍សង្កាត់របស់សង្កាត់បឹងត្របែក។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីធ្វើអោយការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំកាន់តែមានភាពងាយស្រួលយើងខ្ញុំបានបែកចែកចេញជា៤ជំពូកគឺ៖

* **ជំពូកទី១** "រំលឹកទ្រឹស្តីដែលពាក់ព័ន្ធ" ៖ក្រុមយើងខ្ញុំបាន បែងចែកជា៣ចំណុចដោយចំណុចទី១ និយមន័យរបស់សេដ្ឋកិច្ចអភិវឌ្ឍន៍ ចំណុចទី២ លើកឡើងអំពីទ្រឹស្តីរបស់អ្នកសេដ្ឋកិច្ចវិទូ ចំណុចបន្ទាប់ដែលជាចំណុចទី៣ កត្តាជម្រុញដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច។

* **ជំពូកទី២** " ស្ថានភាពទូទៅ និងរចនាសម្ព័ន្ធការគ្រប់គ្រងក្នុងសង្កាត់បឹងត្របែក " ៖ ក្រុមយើងខ្ញុំបានបែងចែកជា៥ចំណុចធំៗ ដោយចំណុចទី១ "ទិដ្ឋភាពទូទៅនៅក្នុងសង្កាត់បឹងត្របែក "ចំណុចទី២" រចនាសម្ព័ន្ធនិងការគ្រប់គ្រងរដ្ឋបាលសង្កាត់បឹងត្របែក" ចំណុចទី៣ "ស្ថានភាពទូទៅ" ចំណុចទី៤ "អភិបាលកិច្ចល្អ និងគណនេយ្យភាព" ចំណុចបន្ទាប់ដែលជាចំណុចទី៥ "ក្រុមប្រឹក្សាសង្កាត់"។

***ជំពូកទី៣** "ស្ថានភាពទូទៅជុំវិញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងសង្កាត់បឹងត្របែក" ៖ក្នុងជំពូកនេះក្រុមយើងខ្ញុំបានបែងចែក២ជាចំណុចដោយក្នុងនោះចំណុចទី១"ស្ថានភាពអភិវឌ្ឍក្នុងសង្កាត់បឹងត្របែក"និង ចំណុចទី២ "ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងឆ្នាំ២០១៨ដល់២០២២" ។

***ជំពូកទី៤** " ការវិភាគទិន្នន័យនៃក្នុងការអភិវឌ្ឍផ្លូវនិងប្រព័ន្ធលូដែលសង្កាត់បឹងត្របែកបានជួសជុលពីឆ្នាំ ២០១៨-២០២២" ៖ ក្រុមយើងខ្ញុំបានបែងចែកជា៤ចំណុច ចំណុចទី១ "ទិន្នន័យផ្លូវដែលសង្កាត់បឹងត្របែកបានជួសជុល" ចំណុចទី២ "ទិន្នន័យលូដែលសង្កាត់បឹងត្របែកបានជួសជុល" ចំណុចទី៣ "បញ្ហាប្រឈមនៃការអភិវឌ្ឍនិងដំណោះស្រាយ"និងចំណុចទី៤" ចំណុចខ្លាំង ចំណុចខ្សោយ"។

# ជំពូកទី១
# រំលឹកទ្រឹស្តី ដែលពាក់ព័ន្ធ

# ជំពូកទី១
# រំលឹកទ្រឹស្តី ដែលពាក់ព័ន្ធ

## ១.១.និយមន័យទូទៅនៃសេដ្ឋកិច្ចអភិវឌ្ឍន៍

### ១.១.១. និយមន័យអភិវឌ្ឍន៍[1]

មុននឹងចាប់ផ្តើមយល់ពីអត្ថន័យនៃសេដ្ឋកិច្ចអភិវឌ្ឍន៍ជាដំបូងត្រូវតែយល់ពីអត្ថន័យនៃពាក្យថាអភិវឌ្ឍន៍ ពាក្យថាអភិវឌ្ឍន៍ត្រូវបានគេអោយនិយមន័យផ្សេងៗគ្នាជាច្រើនដូចជាអភិវឌ្ឍន៍គឺជាដំណើរការនៃការប្រែក្លាយរចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គម វប្បធម៌ និងស្ថាប័ន ដែលបង្កលក្ខណៈងាយស្រួល ឬ អំណោយផលដល់ការធ្វើអោយសេដ្ឋកិច្ចរីកចំរើន និងធ្វើអោយកំណើនសេដ្ឋកិច្ចនេះបន្តបានយូរឬអភិវឌ្ឍន៍ជាការបង្កលក្ខណៈងាយស្រួលអោយមានកំណើនសេដ្ឋកិច្ចចិរភាព ។

អភិវឌ្ឍន៍ ជាដំណើរនៃការធ្វើអោយប្រសើរឡើងខាងគុណភាពនៃការរស់នៅរបស់មនុស្សទាំងអស់ដែលបង្ហាញតាមលក្ខខ័ណ្ឌបីយ៉ាងគឺ :

ក. ការធ្វើអោយប្រសើរឡើងនូវកម្រិតជីវភាពរបស់ប្រជាជនដូចជា : កម្រិតប្រាក់ចំណូល និងការប្រើប្រាស់របស់ប្រជាជនកើនឡើងសេវាសុខាភិបាល អប់រំសិក្សាសាធារណៈ ។ ដោយឆ្លងតាមដំណើរការនៃការទាក់ទងសេដ្ឋកិច្ច ។

ខ.ការបង្កើតលក្ខខ័ណ្ឌដែលនាំអោយមានកំណើននៃការគោរពខ្លួនឯងរបស់មនុស្សដោយឆ្លងតាម រយៈការស្ថាបនាស្ថាប័នសង្គម ស្ថាប័ននយោបាយ ស្ថាប័នសេដ្ឋកិច្ច ។

គ. ការកើនឡើង នៃសេរីភាពក្នុងការប្រើប្រាស់ មានទំហំកាន់តែធំដូចជាប្រជាជនមានសិទ្ធិក្នុងការ ជ្រើសរើសការប្រើប្រាស់ទំនិញ និង សេវា ។

សេដ្ឋកិច្ចអភិវឌ្ឍន៍ គឺជាការសិក្សាពីវិធីរបស់សេដ្ឋកិច្ចដែលត្រូវផ្លាស់ប្តូរពីភាពទ្រឹងទៅជាមានកំណើនសេដ្ឋកិច្ច និង ពីប្រាក់ចំណូលទាបទៅជាមានប្រាក់ចំណូលខ្ពស់ ។

- ការអភិវឌ្ឍ អាចស្តែងចេញតាមមាត្រដ្ឋាន ឬ ទំហំចំនួន ៥ គឺ :

១. មាត្រដ្ឋានសេដ្ឋកិច្ច : ការអភិវឌ្ឍ គឺជាកំណើនសេដ្ឋកិច្ចដោយផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចកែលំអរនិង ពង្រីកប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធទូរគមនាគមន៍ ប្រព័ន្ធថាមពល ប្រព័ន្ធផ្គត់ផ្គង់ទឹក ការពង្រីកវិស័យកសិកម្ម ឧស្សាហកម្មទេសចរណ៍ និង សេវាផ្សេងៗទៀត។

[1] របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាស្តីពីការអភិវឌ្ឍន៍ឃុំ-សង្កាត់តាមបែបវិមជ្ឈការរបស់និស្សិត ម៉ូវ រត្តធូ សុម ពិសិដ្ឋ និងជីម សំនៀងទំព័រ៤

២. មាត្រដ្ឋានសង្គម : ការអភិវឌ្ឍជាការផ្លាស់ប្តូរផ្នែកសង្គមកិច្ចដូចជាសមធម៌និងយុត្តិធម៌តាមរយៈការកាត់បន្ថយភាពក្រីក្រ ដោយធ្វើយ៉ាងណាអោយគម្លាតរវាងអ្នកមាន និង អ្នកក្រ សមល្មមអាចទទួលយកបាន លើកតំកើននារីភេទ ជាពិសេសនោះ ធានាសមភាពរវាងមនុស្សប្រុស និងមនុស្សស្រីក្នុងសង្គម។

៣. មាត្រដ្ឋាននយោបាយ : ការអភិវឌ្ឍ ត្រូវស្ថិតនៅក្នុងបរិដ្ឋាននយោបាយសមស្របសំរាប់ជំរុញវឌ្ឍនភាពសង្គមតាមរយៈច្បាប់ និង ធានានូវការគោរពសិទ្ធិមនុស្ស ។

៤. មាត្រដ្ឋានបរិដ្ឋាន : ការអភិវឌ្ឍ ត្រូវស្ថិតនៅក្នុងក្របខ័ណ្ឌនៃការយកចិត្តទុកដាក់ថែរក្សាតុល្យភាព បរិដ្ឋាន និងការគ្រប់គ្រងធនធានធម្មជាតិអោយបានឋិតថេរ ។

៥.មាត្រដ្ឋានធនធានមនុស្ស : ការអភិវឌ្ឍផ្សារភ្ជាប់ទៅនឹងការកើនឡើងនៃផលិតភាពពលកម្ម និងកម្រិតចេះដឹងនៃប្រជាជនទូទៅការផ្លាស់ប្តូរបទពិសោធន៍ និងបច្ចេកទេស ការផ្តល់សេវាសុខភាព សាធារណៈ និងការអប់រំប្រជាជនទូទៅ ។

### ១.២.១ គោលបំណងនៃការអភិវឌ្ឍ[2]

➢ **ផ្នែកសេដ្ឋកិច្ច**

ក្នុងមូលដ្ឋានសង្កាត់បឹងត្របែកមានប្រព័ន្ធបង្ហូរទឹកស្អុយហេដ្ឋារចនាផ្លូវថ្នល់ល្អស្អាតជីវភាពរស់នៅរបស់. ប្រជាពលរដ្ឋឲ្យកាន់តែប្រសើរឡើង។

➢ **គោលបំណងអភិវឌ្ឍន៍វិស័យគនាគមន៍**

ប្រព័ន្ធគមនាគមន៍ផ្លូវថ្នល់ និងអគ្គិសនីត្រូវបានជួសជុលថែទាំជាប្រចាំ

➢ **គោលបំណងអភិវឌ្ឍន៍វិស័យសិប្បកម្ម សេវាកម្ម និងអាជីវកម្ម**

លើកទឹកចិត្តដល់សិប្បករ សេវាករ អាជីវករចូលរួមលើកកម្ពស់ក្នុងការផលិត និងបំរើធានាបាននូវគុណភាព សោភ័ណ្ឌភាព សុវត្ថិភាព តាមតម្រូវការទីផ្សារ និងជំរុញឲ្យអនុវត្តន៍តាមច្បាប់អនុញ្ញាតិត្រឹមត្រូវ និងមានស្តង់ដារ។

➢ **គោលបំណងអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម**

ទំនិញ ចំណីអាហារធានាបាននូវគុណភាព និងសុខសុវត្ថិភាពជូនប្រជាពលរដ្ឋទូទៅ។

➢ **គោលបំណងអភិវឌ្ឍន៍វិស័យទេសចរណ៍**

ផ្ទះសំណាក់ សណ្ឋាគារ ភោជនីយដ្ឋាន អាហារដ្ឋាន ក្លឹបកំសាន្ត បៀកាខ្ទែន ខារ៉ាអូខេ ត្រូវអនុវត្តទៅតាមច្បាប់បានអនុញ្ញាតិ និងបំផុសចលនាចូលរួមប្រឡងប្រណាំងទីក្រុងស្អាត។

[2] ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០១៨-២០២២) សង្កាត់បឹងត្របែកទំព័រទី២០-ទំព័រទី២១

- **គោលបំណងអភិវឌ្ឍន៍វិស័យព័ត៌មាន**

ពង្រឹងការគ្រប់គ្រងនូវប្រព័ន្ធទិន្នន័យស្តីពីស្ថានភាពភូមិ សង្កាត់ប្រកបដោយ គុណភាព តម្លាភាព និង គណនេយ្យភាព។

- **ផ្នែកសង្គមកិច្ច**

ពលរដ្ឋទទួលបាននូវសេវាថែទាំសុខភាពកាន់តែប្រសើរ និងព័ត៌មានចំណេះដឹង ទំនៀមទំលាប់ ប្រពៃណី ប្រកបដោយសេចក្តីថ្លៃថ្នូរ ។

- **គោលបំណងអភិវឌ្ឍន៍វិស័យសុខាភិបាល**

ពលរដ្ឋទទួលបានសេវាថែទាំសុខភាព និងព្យាបាលជម្ងឺទូទៅ។

- **គោលបំណងអភិវឌ្ឍន៍វិស័យអប់រំ**

លើកកម្ពស់គុណភាពអប់រំ កាត់បន្ថយអត្រាកុមារបោះបង់ការសិក្សា។

- **គោលបំណងអភិវឌ្ឍន៍វិស័យវប្បធម៌/ទំនៀមទំលាប់**

លើកកំពស់សិលធម៌សង្គម អប់រំប្រជាពលរដ្ឋយល់ដឹងវប្បធម៌ទំនៀមទំលាប់ប្រពៃណីខ្មែរ

- **គោលបំណងអភិវឌ្ឍន៍វិស័យសង្គមកិច្ច**

ពង្រឹងការងារសមាគមន៍មនុស្សចាស់ និងជួយដល់គ្រួសារជនងាយរងគ្រោះ

- **គោលបំណងអភិវឌ្ឍន៍វិស័យព័ត៌មាន**

ពលរដ្ឋមានសិទ្ធិទទួលបានព័ត៌មានទាន់ពេលវេលា និងទាន់ហេតុការណ៍

- **គោលបំណងអភិវឌ្ឍន៍ពង្រឹង/កសាងសមត្ថភាពយេនឌ័រ**

ពលរដ្ឋយល់ដឹងពីសមភាពយេនឌ័រ និងចូលរួមការងារសង្គម

- **ផ្នែកគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ**

ពលរដ្ឋរស់នៅគោរពច្បាប់ តាមការណែនាំនៃការអភិវឌ្ឍបរិស្ថាន រួមចំណែកកាត់បន្ថយការបំពុល បរិស្ថាន ចូលរួមរក្សាបរិស្ថានលំនៅដ្ឋានបានល្អ នាំឲ្យមានជាសុខភាព។

- **គោលបំណងអភិវឌ្ឍន៍វិស័យធនធានធម្មជាតិ និងបិស្ថាន**

កាត់បន្ថយនៃការដក់ទឹកនៅលើផ្លូវ និងសម្រាមកកស្ទះ ស្អុយរលួយ

- **គោលបំណងអភិវឌ្ឍន៍ការប្រែប្រួលអាកាសធាតុ**

កាត់បន្ថយការបំពុលបរិស្ថានហេតុដែលនាំឲ្យមានការប្រែប្រួលអាកាសធាតុ

- **ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

ធានាបាននូវប្រសិទ្ធភាពការងាររដ្ឋបាល ផ្តល់សេវាទាន់ពេល រក្សាសន្តិសុខសណ្តាប់ធ្នាប់សុវត្ថិភាព

សង្គម និងពង្រឹងសមត្ថភាពជំនាញ ។

- **គោលបំណងអភិវឌ្ឍន៍វិស័យរដ្ឋបាល**

ពង្រឹងការគ្រប់គ្រងរដ្ឋបាលមានប្រសិទ្ធិភាព តម្លាភាព គណនេយ្យភាពនិងទាន់ពេលឆាប់រហ័ស។

- **គោលបំណងអភិវឌ្ឍន៍វិស័យសន្តិសុខសណ្តាប់ធ្នាប់**

អនុវត្តគោលនយោបាយភូមិសង្កាត់មានសុវត្ថិភាពឲ្យកាន់តែប្រសើរឡើង ធានាដល់ការរស់របស់ប្រជាពលរដ្ឋគ្មានការភ័យខ្លាច។

- **គោលបំណងអភិវឌ្ឍន៍សេវាកម្មរដ្ឋបាល**

ខិតខំពង្រឹងសមត្ថភាពផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងៗ ជូនប្រជាពលរដ្ឋបានគ្រប់ៗគ្នានិងឆាប់រហ័ស។

## ១.២.ទ្រឹស្តីនៃការអភិវឌ្ឍ របស់អ្នកសេដ្ឋកិច្ចវិទូ

### ១.២.១. ទ្រឹស្តីកំណើនលោក ( Walt Withman Roston )[3]

លោក W.W Rostow បានវែកញែកដំណាក់កាលសំខាន់របស់កត្តារចនាសម្ព័ន្ធនៅក្នុងការអភិវឌ្ឍជាប្រាំដំណាក់កាលដោយគាត់បានអះអាងថាគ្រប់ប្រជាជាតិទាំងអស់អាចនឹងឈានដល់កំរិតការអភិវឌ្ឍប្រសិនគេដើរតាមគន្លងប្រទេសអភិវឌ្ឍន៍ ហើយរក្សាលក្ខណៈក្នុងការធានាអោយមានកំណើនសេដ្ឋកិច្ចបានយូរអង្វែង។ ទ្រឹស្តីនេះចែកជាប្រាំដំណាក់កាលនៃការអភិវឌ្ឍន៍ដូចជា សង្គមប្រពៃណី : គឺជាសង្គមមួយដែលគ្មានកំណើនទាល់តែសោះហើយការផលិតធ្វើឡើងតែរៀងៗខ្លួនដូច្នេះផលដែលទទួលបានមានកំរិតទាប។ ប្រជាជនយកមុខរបរកសិកម្មជាវិស័យចំបងក្នុងការផលិតហើយពួកគេមិនមានគំនិតក្នុងការផ្លាស់ប្តូរអ្វីៗទាំងអស់គឺបណ្តោយតាយថាកម្ម ។

លក្ខណៈដែលធ្វើអោយមានការអភិវឌ្ឍ : វានឹងទៅដល់កាលណាបើមានការរួមបញ្ចូលឥទ្ធិពលពិតប្រាកដដែលធ្វើអោយមានផលចំណេញសង្គម ដែលការផ្លាស់ប្តូរនេះត្រូវបានដាក់ចេញមានដូចជា៖

- ការពង្រីកហេដ្ឋារចនាសម្ព័ន្ធ
- ការធ្វើអោយប្រសើរឡើងផ្នែកបច្ចេកវិជ្ជា (ត្រូវតែបង្ខំអោយលឿនជាពិសេសក្នុងវិស័យកសិកម្ម )
- ការធ្វើអោយប្រជាជនមានភាពជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុ ព្រមទាំងធ្វើអោយកើនឡើងនៃសន្សំ

---

[3] របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាស្តីពីការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវរបស់និស្សិត ឡាយ សុវណ្ណ និងហោសាងសាង ឆ្នាំ២០១៣ទំព័រទី១៣-១៤

- វិនិយោគជាប្រទេសដែលស្ថិតនៅក្នុងចន្លោះអន្តរកាលនៃការអភិវឌ្ឍន៍ ។
- ដំណាក់កាលនៃការកើនឡើងនៃការអភិវឌ្ឍន៍
- វិស័យអត្ថិភាពនៃសេដ្ឋកិច្ចបានចាប់កំណើន និងរីកធំធាត់ជាលំដាប់
- កំណើនសេដ្ឋកិច្ចក្លាយទៅជាបញ្ហាសាមញ្ញ
- អាចរក្សាបានស្វ័យប្រវត្តិនូវស្ថេរភាពសេដ្ឋកិច្ចប្រសិនបើប្រទេសទាំងឡាយ មានចំនុចខាងលើ គេហៅ ប្រទេសឧស្សាហកម្មថ្មីដោយពឹងផ្អែកលើ :
- ភាពខ្លាំងក្លានៃអត្រាវិនិយោគ
- អត្ថិភាពនៃនយោបាយ និងស្ថាប័នដែលនាំអោយមានការរំកិលនៃកំណើន
- ការបង្កើតនៅឧស្សាហកម្មសំខាន់ៗ ដើម្បីជាការផ្លាស់ប្តូរ ។

➢ ដំណាក់កាលទុំ

ការអភិវឌ្ឍន៍បានជ្រាបចូលទៅគ្រប់ច្រកល្ហកនៅក្នុងផ្ទៃប្រទេសជាពិសេសគឺវិស័យថ្មីៗនៃផលិតកម្មដែលបានលេចឡើងជារចនាសម្ព័ន្ធនៃការផលិតបានចេញពីវិស័យកសិកម្មទៅឧស្សាហកម្ម។ ការអភិវឌ្ឍចេះតែឈានទៅមុខឧស្សាហកម្មដែលមានវ័យចំណាស់ ត្រូវបានផ្លាស់ប្តូរចេញដោយធ្វើវាអោយមានភាពកាន់តែទំនើបថែមទៀត ឬវិស័យឧស្សាហកម្មថ្មី។

➢ ដំណាក់កាលនៃបំរើបំរាស់ក្នុងទ្រង់ទ្រាយធំ

ការផលិតទំនិញនិងសេវានៅក្នុងគោលបំណងប្រើប្រាស់ចុងក្រោយត្រូវបានធ្វើនៅលើវិស័យឧស្សាហកម្មនៃផលិតកម្មទំនិញ។ដោយសារចំណូលរបស់ប្រជាជនកើនឡើងបានអនុញ្ញាតដល់ការប្រើប្រាស់ក្នុងទ្រង់ទ្រាយធំ នៃទំនិញដែលមិនមែនភាពចំបាច់ត្រង់ចំនុចនេះបញ្ជាក់ថា ការអភិវឌ្ឍកំពុងតែចាប់ផ្តើមដំណើរការខ្លាំងព្រោះថា នៅត្រង់ចំណុចកើនធ្វើអោយ :

- សេចក្តីត្រូវការជាមូលដ្ឋានត្រូវបានដោះស្រាយជាស្ថាពរ
- មានការអភិវឌ្ឍវិស័យសុខមាលភាពសង្គម
- អំណាចសេដ្ឋកិច្ចត្រូវបានពង្រីក។

លោក W.W Rostow បានយកចិត្តទុកដាក់នូវភាពសំខាន់នៃការរីកសាយភាយនៃគ្រឿងយន្តដែល មានតម្លៃថោកដែលធ្វើអោយមានឥទ្ធិពលដល់ជីវិតនៃសង្គមការបែងចែកប្រាក់ចំណូលថ្មី និងបង្កើតប្រព័ន្ធគ្រោង ទុកនៃសង្គម ។

**១.២.២.ទ្រឹស្តី** Anglo-Saxon[4]

នៅខាងផ្នែក Anglo-Saxonបានធ្វើការសិក្សាអំពី" អភិវឌ្ឍន៍" ដោយបានធ្វើការថ្លឹងថ្លែងទៅ លើបញ្ហាលំនឹងរយៈពេលវែងលំនឹងរយៈពេលខ្លី និង លំនឹងនៃវិសាលភាពរបស់សេដ្ឋកិច្ចមានដូចជា កំណើនអតិផរណាលំនឹង ជញ្ជីងពាណិជ្ជកម្ម និកម្មភាព តុល្យភាពថវិកាដោយបានលើកយកតែអំណះអំណាងដែលសំខាន់ៗ។ ក្នុងន័យនេះ ប្រព័ន្ធ Anglo-Saxon អោយសារៈសំខាន់ទៅលើបរិមាណដែលជានិច្ចកាលវាវិបាកសំរាប់ការថយចុះពីការសិក្សា ទៅការអភិវឌ្ឍនិងព្យាករណ៍ទៅលើផលិតផលជាតិពុល (GNP)ទៅលើការវិវត្តន៍ និង ការឈានឡើងរបស់វា។ ហេតុនេះហើយលោក Simon Kuznets អភិវឌ្ឍន៍វាត្រឡប់ទៅរកការពិនិត្យលើ GDP ឬ GNP ក្នុង ប្រជាជនម្នាក់ៗ ។ ទស្សនៈពហុទំហំនៃការអភិវឌ្ឍន៍ពុំមែនគ្មាននោះទេ ក៏ប៉ុន្តែសេដ្ឋកិច្ចវិទូ Anglo-Saxon យល់នាការពិនិត្យទៅលើផលិតផលក្នុងស្រុកដុល របស់ប្រជាជនម្នាក់១ (GDP per capital) ជាមធ្យោបាយ ដ៏ល្អប្រសើរជាងគេក្នុងការកំនត់អត្ថន័យនៃពាក្យ " អភិវឌ្ឍន៍ " ដូចដែលលោក J.Brouton) បានលើកឡើងថា "ការអភិវឌ្ឍ គឺជាសញ្ញាណនៃពហុទំហំដ៏មានសារៈសំខាន់មួយ ក៏ប៉ុន្តែវាមិនចាំបាច់ធ្វើការសិក្សាជាមួយនឹងការ វាស់ពហុទំហំនោះទេក្នុងគ្រប់ករណីផលិតផលក្នុងមនុស្សម្នាក់ៗគឺជាអ្នកជំនួសដ៏មានប្រសិទ្ធភាព "។

**១.២.៣.ទ្រឹស្តី** Lewis[5]

ម៉ូដែលពីស៊ិចរបស់ Lewis បានក្លាយជាទ្រឹស្តីទូទៅនៃដំនើរការសេដ្ឋកិច្ចអភិវឌ្ឍន៍ក្នុងបណ្តា ប្រទេសតតិយលោកដែល មានពលកម្មលើសនាកំឡុងទសវត្សទី៦០ និង ៧០។ ទ្រឹស្តីនេះនៅតែមានអ្នកគាំទ្រ ជាច្រើននាពេលសព្វថ្ងៃនេះ ពិសេសក្នុងចំនោមសេដ្ឋកិច្ចវិទូអភិវឌ្ឍន៍ជនជាតិអាមេរិក។ក្នុងម៉ូដែលរបស់លោក Lewis សេដ្ឋកិច្ចវិទូអភិវឌ្ឍន៍មានពីរស៊ិចទ័រ គឺ ស៊ិចទ័រកសិកម្មប្រពៃណី និង ស៊ិចទ័រឧស្សាហកម្មទីក្រុង។ ស៊ិចទ័រប្រពៃណី គឺជាស៊ិចទ័រយថាផល តាមជនបទ ដែលមានប្រជាជន លើសមានលក្ខណៈសំខាន់ ដោយផលិតភាពផលិតកម្មម៉ាស៊ីណាល់ (Marginal Productive) ស្មើសូន្យគឺជា ស្ថានភាពមួយដែលអនុញ្ញាតអោយ Lewis កំណត់ថាមាន "ពលកម្មលើស " ក្នុងអត្ថន័យដែលគេអាចដក កំលាំងពលកម្មចេញពីស៊ិចទ័រកសិកម្មដោយគ្មានការបាត់បង់ ផលិតផលឡើយ ។ ឯស៊ិចទ័រកសិកម្មទីក្រុង ដែលមាន ផលិតភាពខ្ពស់មានលំហូរកំលាំង ពលកម្មបន្តិចម្តងចេញពីស៊ិចទ័រយថាផល។ ចំពោះម៉ូដែលនេះ គេផ្តោតអារម្មណ៍ជាចំបង ទាំងលើដំណើរការនៃការផ្ទេរកម្លាំងពលកម្ម និង កំណើនផលិតផល ព្រមទាំងកំណើនអនិកម្ម ភាពនៅក្នុងស៊ិចទ័រទំនើប ទាំងការផ្លាស់ប្តូរកំលាំងពលកម្ម និង កំណើនអនិកម្មភាពនៃស៊ិចទ័រទំនើបជាលទ្ធផលនៃ ការ ពង្រីកផលិតផលក្នុងស៊ិចទ័រទំនើប។

[4] របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាស្តីពីដំណើរការអភិវឌ្ឍន៍ឃុំទឹកល្អក់ស្រុកគងពិសី ខេត្តកំពង់ស្ពឺរបស់និស្សិតឈ្មោះសេង ធារី សុន ចំរុង និងអុន ធារិទ្ធទំព័រទី៦-ទំព័រទី៧

[5] របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាស្តីពីដំណើរការអភិវឌ្ឍន៍ឃុំទឹកល្អក់ស្រុកគងពិសី ខេត្តកំពង់ស្ពឺរបស់និស្សិតឈ្មោះសេង ធារី សុន ចំរុង និងអុន ធារិទ្ធទំព័រទី៨

ល្បឿននៃការពង្រីកនេះកំណត់ដោយអត្រាវិនិយោគរបស់សហគ្រាស និង សមោហធនមូលធន ក្នុងស៊ិចទ័រទំនើប។ វិនិយោគបែបនេះកើតមានឡើងដោយសារមានភាពលើសស៊ិចទ័រ ទំនើប ។ ល្បឿននៃការពង្រីកនេះកំណត់ដោយអត្រាវិនិយោគរបស់សហគ្រាសនិង សមោធនមូលធនក្នុងស៊ិចទ័រ ទំនើប។ វិនិយោគបែបនេះកើតមានឡើង ដោយសារមានភាព លើសនៃប្រាក់ចំណេញរបស់ស៊ិចទ័រទំនើបពីប្រាក់ ខែ ដោយសន្មតថា ពួកមូលធនវិនិយោគ ឡើងវិញនូវប្រាក់ចំណេញរបស់ពួកគេ។ ជាចុងក្រោយគេសន្មតថាកំរិត ប្រាក់ខែក្នុង ស៊ិចទ័រ ឧស្សាហកម្មទីក្រុងនៅថេរ ហើយត្រូវកំណត់ថា ប្រាក់បន្ថែមពីលើ ដែលគេព្រមព្រៀងលើ កំរិតប្រាក់ខែ ត្រឹមតែរស់ជាមធ្យមថេរ ( Fixed Average Subsistence Level of Wages ) ក្នុងស៊ិចទ័រកសិកម្មប្រពៃណី។ (Lewis បានសន្មត់ថា ប្រាក់ខែនៅទីក្រុង ត្រូវខ្ពស់ជាងប្រាក់ខែជាមធ្យមតាម ជនបទចំនួន ៣០ % ដើម្បីទាក់ទាញ កម្មករអោយផ្លាស់ទីពីភូមិស្រុករបស់ពួកគេ )។ ចំពោះប្រាក់ខែថេរនៅតាមទីក្រុងខ្សែកោងផ្គត់ផ្គង់នៃកំលាំងពលកម្មជនបទអោយទៅជាស៊ិចទ័រទំនើប ត្រូវបានគេចាត់ទុកថាមានភាពយឺតពេញលេញ ។

**១.២.៤.ទ្រឹស្តី** Michael P. Todaro[6]

ការអភិវឌ្ឍអាចកើតឡើងនិងប្រកបដោយចីរភាពវាត្រូវចាប់ផ្តើមពីតំបន់ជនបទជាពិសេសនៅក្នុងវិស័យកសិកម្ម។ នេះជាទ្រឹស្តីរបស់លោក Michael P. Todaro ដែលលោកបានលើកឡើងថាប្រជាជាតិមួយអាចទៅដល់ការអភិវឌ្ឍយ៉ាងហោចណាស់មានកត្តាចំនួនបីយ៉ាងដូចខាងក្រោម៖

ក.ការពន្លឿនអូវកុតតាមរយៈការធ្វើកំណែទំរង់ថ្លៃស្ថាប័ននិងបច្ចេកវិទ្យាដែលត្រូវបានរៀបចំឡើងដើម្បីបង្កើនផលិតភាពសម្រាប់កសិករតូចតាច។

ខ.បង្កើនតម្រូវការក្នុងស្រុកសម្រាប់ផលិតផលកសិកម្មដែលមានប្រភពមកពីយុទ្ធសាស្ត្រអភិវឌ្ឍការងារតំបន់ជាយក្រុង។

គ.សកម្មភាពអភិវឌ្ឍជនបទដើម្បីពង្រីកកម្លាំងពលកម្មមិនមែនកសិកម្មនិងវិស័យដទៃផ្សេងៗទៀតដែលគាំទ្រដោយផ្ទាល់ឬប្រយោលពីសហគមន៍កសិកម្ម។

**១.២.៥.ទ្រឹស្តី** Solow[7]

នៅក្នុងឆ្នាំ១៩៥២ Robert Solow បានចេញផ្សាយអត្ថបទមួយក្នុងទ្រឹស្តី American Economic Review ដោយដាក់ចំណងជើងថា. A Contribution to Economic Theory of Growth" ។ វិភាពទានប្រស់ Solow

[6] របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាស្តីពីដំណើរការអភិវឌ្ឍន៍ឃុំទឹកល្អក់ស្រុកគងពិសី ខេត្តកំពង់ស្ពឺរបស់និស្សិតឈ្មោះសេង ធារី សុន ចំរុង និងអុន ធារិទ្ធទំព័រទី៧

[7] Econimic Development. Mechael P. TODARO,Fitfth Edition 1994, Pagr70

នៅក្នុងទ្រឹស្តីកំណើនសេដ្ឋកិច្ចនេះគឺការបកស្រាយយ៉ាសាមញ្ញមួយអំពីកត្តាដែលនាំអោយមានកំណើនសេដ្ឋកិច្ច កត្តាដែលធ្វើអោយកំរិតជីវភាពរបស់ប្រជាពលរដ្ឋក្នុងប្រទេសមួយខ្ពស់ជាងប្រទេស មួយទៀត ហើយនឹងការជាប់កាំងដំណើរការរីកចម្រើននៃសកម្មភាពសេដ្ឋកិច្ច ។

➢ សំនួរទី១បានចោទឡើងថា : ហេតុអ្វីបានជាប្រទេសមួយមាន ហើយប្រទេសមួយទៀតក្រ ?

Solowបានអះអាងថា:ប្រទេសមួយមានរីឯប្រទេសមួយទៀតក្រគឺដោយសារតែកំរិតចំនូលក្នុងពលរដ្ឋ ម្នាក់ៗប្រទេសមានដោយសារចំនូលក្នុងពលរដ្ឋម្នាក់ខ្ពស់ រីឯប្រទេសក្រដោយសារចំនូលក្នុងពលរដ្ឋម្នាក់ទាប។ ដូចនេះចំនូលក្នុងពលរដ្ឋម្នាក់ជាសូចនាករណ៍ដ៏សំខាន់ចង្អុលបង្ហាញពី កំរិតជីវភាពរបស់ប្រជាជនម្នាក់ៗ។ចំណូលក្នុងពលរដ្ឋម្នាក់ វាស្រ័យទៅនឹងមូលធនក្នុងពលរដ្ឋម្នាក់បើមូលធនក្នុងពលរដ្ឋម្នាក់កើននោះចំនូលក្នុងពលពលរដ្ឋម្នាក់ក៏ កើនឡើងដែរ ។

➢ សំនួរទី២បានចោទឡើងថា : ហេតុអ្វីបានជាមូលធនក្នុងពលរដ្ឋម្នាក់របស់ប្រទេសមួយខ្ពស់ជាងមូលធនក្នុងពលរដ្ឋម្នាក់របស់ប្រទេសមួយទៀត ?

Solowបានបកស្រាយទៅនឹងសំនួរថា:បានជាមូលធនក្នុងពលរដ្ឋម្នាក់របស់ប្រទេសមួយខ្ពស់ជាងមូលធនក្នុងពលរដ្ឋម្នាក់របស់ប្រទេសមួយទៀត គឺដោយសារប្រទេសនោះមានអត្រាសន្សំខ្ពស់ហើយមានអត្រាកំណើនពលរដ្ឋក្នុងប្រទេសទាប។ដូចនេះកាលណាអត្រាសន្សំខ្ពស់នោះការវិនិយោគកាន់តែខ្ពស់ នាំអោយសេដ្ឋកិច្ច មានកំណើននោះការអភិវឌ្ឍន៍កាន់តែប្រសើរឡើង៉ ។

## ១.៣.កត្តាជម្រុញដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច[8]

កត្តាដែលនាំអោយមានការអភិវឌ្ឍន៍មានដូចខាងក្រោម :

**ក. កត្តាពលកម្ម** :សំដៅលើចំនួនប្រជាពលរដ្ឋសកម្មដែលមាននៅក្នុងប្រទេសនាខណៈពេលមួយ ។ ពលរដ្ឋសកម្មជាពលរដ្ឋដែលស្ថិតនៅវ័យពលកម្មគ្រប់គ្រាន់ស្ម័គ្រចិត្តបំពេញការងារតាមទីផ្សារបច្ចុប្បន្ន។ ប្រជាពលរដ្ឋសកម្ម គឺពលកម្មដែលមានជំនាញខ្ពស់ និងទទួលបានបទពិសោធន៍ច្រើន ។ ជាពិសេស ប្រជាពលរដ្ឋសកម្ម គឺពលកម្មដែលមានជំនាញខ្ពស់ និងទទួលបានបទពិសោធន៍ច្រើន។

**ខ. ធនធានធម្មជាតិ** : មនុស្សទូទៅពេលដែលគេចាប់ផ្តើមនិយាយពីធនធានធម្មជាតិគឺសំដៅលើបរិស្ថាន។បរិស្ថាននៅទីនេះគេចង់សំដៅលើធនធានដែលមាននៅលើនិងក្រោម ដីត្រូវយកមកប្រើជាកត្តាផលិតកម្ម ។ ឧទាហរណ៍ : ផលិតផលព្រៃឈើ នេសាទ ផ្ទៃដីដាំដុះ៖ គឺជានធនធាននៅលើដី រីឯរ៉ែគ្រប់ប្រភេទដូចជា រ៉ែដែក ប្រេងកាតជាធនធានក្រោមដី ។

---

[8] របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាស្តីពីផែនការអភិវឌ្ឍន៍ខេត្តពោធិ៍សាត់របស់និស្សិតទំព័រទី១២-១៣-១៤

**គ. បច្ចេកវិទ្យា** : សំដៅលើសំណុំនៃចំណេះដឹងក្នុងការផលិតក្នុងខណៈពេលមួយ ។ បច្ចេកវិទ្យាត្រូវមាន វត្តមានចាំបាច់គ្រប់ករណីផលិតកម្មទាំងអស់ ព្រោះថាបើគ្មានបច្ចេកវិទ្យាគេពុំដឹងពីមធ្យោបាយក្នុងការផ្សំវត្ថុធាតុ ដើមអោយចេញជាផលិតផលសំរេចបានឡើយ ។

**ឃ. មូលធន** : សំដៅលើស្តុកនៃមធ្យោបាយ និងឧបករណ៍សំភារៈនានាដែលមាននៅក្នុងខឿនសេដ្ឋកិច្ច មួយក្នុងខណៈពេលមួយសំរាប់ប្រើប្រាស់ក្នុងការផលិត។ ដែលរាប់បញ្ចូលទៅក្នុងមូលធនដូចជា : អាគារ រោងចក្រ បណ្តាញផ្លូវថ្នល់ ប្រព័ន្ធចែកចាយអគ្គិសនី គ្រឿងចក្រ និងឧបករណ៍ដទៃទៀត ។ ជារួមយើងអាចអោយ និយមន័យទៅលើមូលធនថា ជាកត្តាផលិតកម្មដែលចូលរួមក្នុងការផលិតបានច្រើនដង ហើយផ្ទេរតំលៃរបស់វាបន្តិចម្តងៗទៅក្នុងទំនិញដែលផលិតថ្មីហៅថារំលស់ ។

**ង. សហគ្រិនភាព** ( **ការគ្រប់គ្រង**): សំដៅលើគោលនយោបាយដឹកនាំគ្រប់គ្រងរបស់អ្នកគ្រប់គ្រង ។ ជាទូទៅការគ្រប់គ្រងត្រូវបានគេសរសេរក្នុងរូបភាពជាមេគុណាអនុគមន៍ផលិតកម្ម ។

**ច. លក្ខខ័ណ្ឌសង្គម** : ត្រូវគោរពអោយបាននូវលក្ខខ័ណ្ឌសំខាន់ៗ៤យ៉ាងដូចខាងក្រោម :

-អភិបាលកិច្ចល្អ : សំដៅលើការគ្រប់គ្រងរបស់រដ្ឋាភិបាលទាំងវិស័យសាធារណៈ និងឯកជន ។

-លំនឹងម៉ាក្រូសេដ្ឋកិច្ច : ត្រូវរក្សាអោយបាននូវអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ អត្រាអតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថេរភាព ។

-លំនឹងជញ្ជីងពាណិជ្ជកម្ម សំដៅលើការនាំចេញ និងការនាំចូលអោយមានអត្រាប្រហាក់ប្រហែលគ្នា រឺក៏ការនាំចេញធំជាងការនាំចូលកាន់តែប្រសើរ ។

-លំនឹងថវិការជាតិ : សំដៅលើការចំណាយសាធារណៈ និងចំណូលរដ្ឋ ។

### ១. ៣. ១ ធនធានមនុស្ស

ប្រជាជនគឺជាកំលាំងពលកម្មមួយយ៉ាងសំខាន់ក្នុងដំណើរការផលិតកម្ម។ ហេតុនេះហើយប្រជាជនត្រូវបានពិចារណាថា ជាកត្តាវិជ្ជមានក្នុងការជំរុញអោយមានកំណើនសេដ្ឋកិច្ច។

ចំនួនដែលកើនឡើយរបស់ប្រជាជនបានធ្វើអោយមានការកើនឡើងទំហំទីផ្សារសក្តានុពលក្នុងប្រទេសផងដែរ។ ទំហំទីផ្សារដ៏ទូលាយនេះអាចអោយ យើង អនុវត្តសេដ្ឋកិច្ចមាត្រដ្ឋានបានពោលគឺ ប្រជាជនមានឯកទេសកម្មដ៏ប៉ិនប្រសព្វនៅក្នុងផលិតកម្ម និងម៉ាឌីទីង លោកScholars-EsterBoserupបានលើកឡើងថាកំណើនដង់ស៊ីតេប្រជាជនគឺជាកត្តាលីករមួយសំរាប់ធ្វើអោយ មានការឆ្នៃប្រឌិតនិងវិធីសាស្ត្រថ្មីក្នុងអង្គភាពអាជីវកម្ម។ ការកើនឡើងចំនួនប្រជាជននៅទ្វីបអាមេរិកខាងជើង នៅក្នុងសតវត្សទី ១៩ និងប្រទេសអូស្ត្រាលីនៅដើមសតវត្សទី ២០ បានបង្កើតអោយមានការប្រើប្រាស់ប្រកប ដោយប្រសិទ្ធិភាពនៃធនធាន ដែលធម្មជាតិផ្តល់អោយ និងធ្វើអោយមានការអភិវឌ្ឍន៍ទីផ្សារយ៉ាងទូលំទូលាយ ជាមួយនឹងការយល់ដឹងពីសេដ្ឋកិច្ចមាត្រដ្ឋានទាំងអស់នេះបានបំរើ

អោយមានការកើនឡើងនូវបំលាស់ប្តូរខាងផ្នែក បច្ចេកវិទ្យា។ កំណើនប្រជាជនកើនឡើងនឹងធ្វើអោយតំរូវការកើនឡើង ដែលនាំអោយផលិតផលជាតិសរុបកើន ឡើងជាចុងក្រោយនឹងធ្វើអោយប្រទេសកាន់តែអភិវឌ្ឍន៍ឡើង។ ផ្លូវជាតិនិងផ្លូវដែកកើនឡើងជាមួយនឹងដង់ស៊ីតេ ប្រជាជនខ្ពស់ ដោយរួមចំណែកពីរចនាសម្ព័ន្ធនៃតំបន់ផ្សេងៗទៀតដូចជា សេវាសុខាភិបាល ការអប់រំ ធារាសាស្ត្រ ទូរគមនាគមន៍ សេវាកម្មពង្រីក និងទីផ្សារ យ៉ាងហោចណាស់ត្រូវបានបង្កើតដើម្បីទ្រទ្រង់នឹងកំណើនប្រជាជននោះ តំរូវការខ្ពស់មានន័យថាហានិភ័យដែលកើតលើការវិនិយោគទុន និងការវិនិយោគដ៏ធំសំបើមបាននាំមកនូវការកែច្នៃ គុណភាពដី ការអប់រំ បង្កើនឡើងបច្ចេកវិទ្យាទាំងអស់នេះមានន័យថា បង្កើននូវផលិតភាពកម្ម ។

### ១.៣.២.ធនធានមូលធន

ដំណើរការដំបូងនៅក្នុងការអភិវឌ្ឍ គឺការបង្កើតមូលធនតាមរយៈការសន្សំ និងវិនិយោគ ។ អ្នកសេដ្ឋកិច្ចអភិវឌ្ឍន៍សម័យមុនបានគិតថាមូលធនគឺជាកត្តាសំខាន់បំផុតនៅក្នុងដំណើរការនៃការអភិវឌ្ឍន៍ ហើយកេរដំនែលនេះវាបន្តហូតមកដល់បច្ចុប្បន្ន។ ពិតណាស់វាមានសមត្ថភាពបង្កើនផលិតភាពពលកម្ម និងបង្កើតនូវតំរូវការពល កម្ម។ មូលធនរូប គឺជាកត្តាសំខាន់សម្រាប់ធ្វើអោយមានកំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ជានៅ ប្រទេសអភិវឌ្ឍន៍ដោយសារថានៅប្រទេសកំពុងអភិវឌ្ឍន៍ មានការអភិវឌ្ឍន៍តិចតួច ដូចនេះបច្ចេកវិទ្យាទំនើបៗពុំអាចអោយគេប្រើប្រាស់បានមានតែមូលធនរូបដ៏ច្រើនសន្ធឹកសន្ធាប់ទេដែលជួយជំរុញដល់កំណើនផលិតកម្មច្រើន។ នៅទសវត្សទី ៥0 លោក W.Arthur Lewis, Walt Withman Rostow និងសេដ្ឋវិទូជាច្រើនទៀត បានបង្កើត ជំហចំពោះសេដ្ឋកិច្ចដែលស្ទះថា ជាធម្មតាត្រូវមានសន្សំ និងវិនិយោគប្រហែល ៥ % នៃចំណូលជាតិ និងចំពោះ៖ សេដ្ឋកិច្ច ដែលមានកំណើនវិញត្រូវមានសន្សំ និងវិនិយោគពី ១២% ទៅ ១៥ % នៃចំណូលជាតិ ។

### ១.៣.៣.ធនធានធម្មជាតិ

ធម្មជាតិគឺសំដៅទៅលើរូបធាតុទាំងឡាយណាដែលត្រូវបានបង្កើតឡើងដោយធម្មជាតិ ឬកើតឡើងដោយឯកឯង ។ចំពោះរូបធាតុទាំងឡាយណាដែលស្ថិតនៅជុំវិញខ្លួនយើង គេហៅថាបរិស្ថានធនធានធម្មជាតិ ដែលរួមមានៈ ធនធានលើដី ក្រោមដី ក្នុងបរិយាកាស និងក្នុងទឹក... ។ល ។

ធនធានធម្មជាតិត្រូវបានប្រើប្រាស់ដើម្បីបំពេញសេចក្តីប្រាថ្នា ឬតំរូវការរបស់មនុស្ស។ ធនធានទាំងនោះ ត្រូវបានប្រើប្រាស់ជាមួយនឹងកត្តាផលិតកម្មដទៃទៀត ដើម្បីបង្កើតជាផលិតផល និងសេវាកម្ម ។ ដូច្នេះ អនុផលិត កម្មយ៉ាងហោចណាស់មានកត្តាផលិតកម្មចំនួន ៤ ចូលរួមក្នុងដំណើរការផលិត។ យើងអាចបង្ហាញនូវអនុគមន៍ផលិតកម្មដូចខាងក្រោមៈ

$Q = f(L, K, D, E)$

នៅក្នុងការវិភាគទ្រឹស្តីទូទៅគេកំណត់កត្តាផលិតកម្មតែចំនួន ៣ ទេ គឺពលកម្ម (L) មូលធន (K) និងដី (D) ដែលត្រូវបានគេប្រើក្នុងផលិតកម្មប៉ុន្តែក្នុងការវិភាគអោយបានច្បាស់ជាងនេះគឺគេបញ្ចូលកត្តាទី៤ មួយទៀត គឺថាមពល(E) ។ នៅក្នុងអនុគមន៍ផលិតកម្មខាងលើនេះបង្ហាញអោយឃើញថា មានការប្រើប្រាស់នូវធនធានធម្ម ជាតិរួមមានដីនិងថាមពលជាដើម។ ដី និង ទឹក ដែលទទួលបានពីការផ្តល់ដោយធម្មជាតិនេះ មានលក្ខណៈជាទំរង់ ពីរគឺ ធនធានដែលអាចបង្កើតឡើងវិញបានដូចជា ព្រៃឈើ ផលផល និងធនធានដែលពុំអាចបង្កើតឡើងវិញបាន ដូចជា រ៉ែដែក រ៉ែប្រេងជាដើម។ ធនធានបែបនេះហើយ គឺជាកត្តាផលិតកម្មដែលត្រូវបញ្ចូលទៅក្នុងដំណើរការ ផលិតកម្ម ហេតុនេះទើបធនធានធម្មជាតិ គឺជាអ្នកកំណត់នូវកំណើនសេដ្ឋកិច្ច ព្រោះបរិមាណវាមានកំណត់ ។

ពាក់ព័ន្ធទៅនឹងកំណើនសេដ្ឋកិច្ចតាមរយៈធនធានធម្មជាតិ ការអភិវឌ្ឍប្រកបដោយចិរភាព៍គឺមានសារៈសំខាន់ ដើម្បីធានាអោយមានកំណើនសេដ្ឋកិច្ចយូរអង្វែង ព្រោះវាអាចឆ្លើយតបទៅនឹងតំរូវការធនធានក្នុងថ្ងៃនេះ និងគ្មានឧបសគ្គដល់តំរូវការធនធានក្នុងថ្ងៃស្អែក។ តាមរយៈការអភិវឌ្ឍន៍ប្រកបដោយចិរភាពនេះ បានបង្ហាញថាធនធានធម្មជាតិទាំងនោះ ត្រូវបានគេចាត់ចែងសំរាប់ផលិតកម្មជារៀងរាល់ថ្ងៃ និងពេលអនាគតដោយពុំព្រួយបារម្ភពីការធ្លាក់ចុះនៃស្តុកធនធានធម្មជាតិឡើយ ។

### ១.៣.៤ ការអភិវឌ្ឍប្រកបដោយនិរន្តរភាព[9]

ពាក្យ និរន្តភាព ត្រូវបានគេឲ្យនិយមន័យជាច្រើន ដោយពឹងផ្អែកទៅលើគោលគំនិតផ្សេងៗ របស់អ្នកឯកទេសក្នុងការអភិវឌ្ឍ។ ការឲ្យនិយមន័យសង្កត់ធ្ងន់ទៅលើគំនិតសំខាន់ៗដូចជា៖

- ការអភិវឌ្ឍដែលប្រកបដោយនិរន្តភាពអាចឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងថ្ងៃនេះ ដោយគ្មានឧបសគ្គដល់លទ្ធភាពប្រជាជនដើម្បីបំពេញតម្រូវការរបស់ពួកគាត់នៅថ្ងៃស្អែ ក។ ប្រភពធនធានធម្មជាតិលើផែនដីមានចំនួនកំណត់របស់វា ហើយដើម្បីឲ្យធនធាន ធម្មជាតិទាំងនោះមានជីវិតយូរអង្វែង គឺទាមទារឲ្យមានច្បាប់ការពារគ្រប់គ្រងនិងថែរក្សា និងទាមទារការរៀបចំប្រើប្រាស់ឲ្យមានតុល្យភាពហើយនិងការពារដល់សម្បត្តិធនធាន ធម្មជាតិសម្រាប់តម្រូវរបស់មនុស្សជំនាន់ក្រោយៗទៀត។
- ការអភិវឌ្ឍប្រកបដោយនិរន្តភាពគឺ ផ្តល់អាទិភាពទៅលើការប្រមូលផ្តុំធនធានទាំងអស់ ក្នុងមូលដ្ឋានសម្រាប់ធ្វើការវិនិយោគទុន សម្រាប់ការអប់រំបង្កើនសមត្ថភាព និងជំនាញ បច្ចេកទេសដល់ប្រជាជនដើម្បី៖
- ទទួលខុសត្រូវជីវិតរស់នៅរបស់ពួកគេផ្ទាល់ក្នុងសហគមន៍ និងធនធានដែលមាន ចូលរួមដំណើរការសំរេចចិត្តផ្សេងៗយល់ព្រមក្នុងការបែងចែកនិងការទទួលខុសត្រូវសម្រាប់សុខភាពសហគមន៍ទាំងមូលធ្វើឲ្យមានការ

---

[9] របាយការណ៍បញ្ចប់ការសិក្សាឆ្នាំ ២០០៦ ដំណើរការអភិវឌ្ឍន៍របស់អង្គការអភិវឌ្ឍន៍កសិកម្មកម្ពុជាខេត្តតាកែវ ទំព័រ១២

គោរពការការពារនិងការអភិរក្សបរិស្ថានដើម្បី ថែរក្សាទំនាក់ទំនងមនុស្សនិងធម្មជាតិ។

➢ ការអភិវឌ្ឍប្រកបដោយនិរន្តភាពគឺជាការយកប្រជាជនជាធំ និងត្រូវចាត់ទុកប្រជាជនជា ចំណុចដែលត្រូវយកចិត្តទុកដាក់ខ្លាំងពីព្រោះប្រជាជនជាអ្នកធ្វើឲ្យកើតមានឡើង និងបញ្ជាក់នូវការងារអភិវឌ្ឍន៍មានកំរិត។

### ១.៣.៥ ការអភិវឌ្ឍតាមបែបចូលរួម[10]

ដើម្បីធ្វើឲ្យការអភិវឌ្ឍអាចប្រកបបានដោយនិរន្តភាព គឺត្រូវផ្តោតទៅលើការយកចិត្តទុកដាក់ ដល់ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍លើគ្រប់សកម្មភាពអភិវឌ្ឍន៍រួមទាំងមានការ ស្វែងរកឬសគល់នៃបញ្ហាវិភាគ បញ្ហាការប៉ាន់ប្រមាណលើការធ្វើផែនការ ការអនុវត្តគម្រោងលើ ផែនការ ការត្រួតពិនិត្យ ការតាមដាន និងការវាយតម្លៃលើគម្រោងផែនការជាដើម។

#### ក. និយមន័យនៃការចូលរួម

ការចូលរួមមានន័យថាគឺជាសកម្មភាពរួមគ្នាដើម្បីសម្រេចទិសដៅតែមួយ។ វាមានអត្ថន័យថាមនុស្សម្នាក់ៗដែលមានការចាប់អារម្មណ៍ត្រូវតែធ្វើការចូលរួម។ ម្នាក់ៗត្រូវធ្វើការចូលរួមក្នុងការធ្វើ ផែនការ ការសំរេចចិត្ត ការអនុវត្ត និងការវាយតម្លៃសកម្មភាពតាមមូលដ្ឋានដើម្បីលុបបំបាត់នូវភាព ក្រីក្រនិងដើម្បីធានានូវការអភិវឌ្ឍន៍ជានិរន្តន៍។

#### ខ. កម្រិតនៃការចូលរួម

មួយផងដែរ ដែលប្រជាពលរដ្ឋត្រូវបានគេផ្តល់សិទ្ធិអំណាចក្នុងការទទួលបាននូវជំនាញចំណេះដឹង បទពិសោធន៍ និងធនធានដើម្បីឲ្យពួកគេអាចគ្រប់គ្រងដំណើរការនៃការអភិវឌ្ឍផ្ទាល់ខ្លួនរបស់ពួក គេបាន។ នៅពេលនោះការចូលរួមក្លាយជាយន្តការសម្រាប់ផ្លាស់ប្តូរដែលមានគោលបំណងផ្តល់ឲ្យ អ្នកក្រីក្រនូវធនធានដែលពួកគេត្រូវការក្នុងគោលបំណងលុបបំបាត់នូវភាពក្រីក្រ (UNDP, 1997)។

ការចូលរួមរបស់ប្រជារាស្ត្រតាមមូលដ្ឋានកើតឡើងតាមកំរិតផ្សេងៗគ្នា។ ការចូលរួមកំរិតទាប បំផុតពេលគឺ ប្រជាពលរដ្ឋតាមមូលដ្ឋានគ្រាន់តែត្រូវបានប្រាប់ដោយរដ្ឋអំណាចថ្នាក់លើឲ្យអនុវត្ត នូវគម្រោងកម្មវិធីសហគមន៍របស់គេតែប៉ុណោះ។ ការចូលរួមបន្ទាប់គឺថាគំនិតយោបល់និងសំណូម ពររបស់ប្រជាពលរដ្ឋតាមមូលដ្ឋានត្រូវបានគេយកចិត្តទុកដាក់។ ការចូលរួមមួយកំរិតទៀតគឺថាអ្នក ភូមិត្រូវបានចាត់ទុកជាដៃគូអភិវឌ្ឍន៍។ ការចូលរួមកំរិតខ្ពស់បំផុតនោះ គឺជាទស្សនៈអំពីការផ្តល់សិទ្ធ អំណាចត្រូវបានយល់ជ្រួតជ្រាបហើយប្រជាពលរដ្ឋចាប់ផ្តើមគ្រប់គ្រងស្ថានភាពដែលមានផលប៉ះ ពាល់ទៅលើជីវិតរបស់ពួកគេ។

[10] របាយការណ៍បញ្ចប់ការសិក្សាឆ្នាំ ២០០៥ ដំណើរការអភិវឌ្ឍន៍សហគមន៍ស្រុកសាមគ្គីខេត្តកំពង់ឆ្នាំងទំព័រ១២-ទំព័រ០៧

### គ. គោលការណ៍នៃការអភិវឌ្ឍតាមបែបចូលរួម

ចំណុចសំខាន់របស់យុទ្ធសាស្ត្រនៃការចូលរួមគឺប្រជាបាលរដ្ឋដែលរស់នៅតាមជនបទ។ គ្រប់ ការផ្តួចផ្តើមទាំងអស់ដើម្បីលើកកម្ពស់ការចូលរួមដែលចាប់ផ្តើមដោយតម្រូវការ ការរំពឹងទុកគំនិត យោបល់ដែលត្រូវបានលើកឡើងដោយសមាជិកសហគមន៍តាមមូលដ្ឋានក្រុមមនុស្ស និងគ្រួសារ។ ហេតុដូចនេះ គឺត្រូវគិតនៅពេលដែលធ្វើសេចក្តីសំរេចចិត្តគេត្រូវលើកអាទិភាពនៃការអភិវឌ្ឍរបស់ ប្រជាពលរដ្ឋតាមមូលដ្ឋានខ្លួនឯង។

យុទ្ធសាស្ត្រនៃការចូលរួមគឺធ្វើឲ្យមានការចូលរួមពីសហគមន៍ទាំងមូលរួមទាំងស្ត្រី និងបុរស មិនថា អ្នកមាន អ្នកក្រ សហគ្រិនឯកជន វិទ្យាស្ថានសាធារណៈ អាជ្ញាធរក្នុង និងក្រៅប្រទេសជា ដើម។ ការចូលរួមរបស់ពួកគេត្រូវបានជម្រុញនៅគ្រប់ដំណាក់កាលទាំងអស់ដូចជានៅពេលវិភាគ ស្ថានភាពពេលទិសដៅពេលរៀបចំយុទ្ធសាស្ត្រពេលអនុវត្តន៍និងពេលចុងបញ្ចប់នៅពេលត្រួតពិនិ ត្យតាមដាន និងវាយតម្លៃសកម្មភាពជាប្រចាំ។

# ជំពូកទី២
# ស្ថានភាពទូទៅនិងរចនាសម្ព័ន្ធការគ្រប់គ្រងក្នុងសង្កាត់បឹងត្របែក

# ជំពូកទី២

# ស្ថានភាពទូទៅនិងរចនាសម្ព័ន្ធការគ្រប់គ្រងក្នុងសង្កាត់បឹងត្របែក

## ២.១.ទិដ្ឋភាពទូទៅនៅក្នុងសង្កាត់បឹងត្របែក[11]

សង្កាត់បឹងត្របែក ចែកចេញជា ៨ ភូមិគឺ ភូមិ១ ភូមិ២ ភូមិ៣ ភូមិ៤ ភូមិ៥ ភូមិ៦ ភូមិ៧ និងភូមិ៨ ដែលមានប្រជាពលរដ្ឋសរុបចំនួន ១៤២៩ គ្រួសារ មានមនុស្សសរុបចំនួន ៦៦៧៥ នាក់ ក្នុងនោះស្រីមានចំនួន ៣៣៧៧ នាក់ ចំនួនប្រជាពលរដ្ឋ ចាប់ពីអាយុ ១៨ ឆ្នាំឡើង មានចំនួន ៥១៤៥ នាក់ ក្នុងនោះស្រីមានចំនួន ២៥៨៩ នាក់ ។

### ២.១.១.ស្ថានភាពភូមិសាស្ត្រ[12]

សង្កាត់បឹងត្របែកជាសង្កាត់មួយក្នុងចំណោមសង្កាត់ទាំង១២របស់ខណ្ឌចំការមន មានទីតាំងស្ថិតនៅទិសអាគ្នេយ៍នៃសាលាខណ្ឌចំការមននិងមានចំងាយប្រមាណ១គីឡូម៉ែត្រពីសាលាខណ្ឌ។សង្កាត់នេះស្ថិតលើទីទំនាបជាងសង្កាត់ដទៃទៀតរបស់ខណ្ឌចំការមន ដែលចែកជា ៨ ភូមិ ដែលមាន ព្រំប្រទល់៖

- ខាងកើតជាប់សង្កាត់ទន្លេបាសាក់
- ខាងត្បូងជាប់សង្កាត់ផ្សារដើមថ្កូវ
- ខាងលិចជាប់សង្កាត់ទួលទំពូងទី១
- ខាងជើងជាប់សង្កាត់បឹងកេងកងទី៣

សង្កាត់បឹងត្របែកជាសង្កាត់ដែលស្ថិតនៅក្នុងរាជធានីភ្នំពេញដែលស្ថិតនៅក្នុងរាជាធានីភ្នំពេញ។ ( មើលឧបសម្ព័ន្ធទី១ )

## ២.២.រចនាសម្ព័ន្ធ និការគ្រប់គ្រងរដ្ឋបាលសង្កាត់[13]

ការគ្រប់គ្រងមួយអាចប្រកបទៅដោយប្រសិទ្ធភាព គឺអាស្រ័យទៅលើថ្នាក់ដឹកនាំរបស់ខ្លួនដែលមាន សមត្ថភាពក្នុងការដឹកនាំត្រូវបានធ្វើការបែងចែកនូវតួនាទីភារកិច្ច ទៅតាមផ្នែកជំនាញបច្ចេកទេសរបស់បុគ្គលិក។ម្យ៉ាងទៀតការគ្រប់គ្រងរដ្ឋបាលវិញក៏មិនខុសគ្នាដែរ គឺត្រូវមានការបែងចែករចនាសម្ព័ន្ធ នៃការគ្រប់គ្រងហើយមានការកំណត់ពីតួនាទី ភារកិច្ច និងសិទ្ធិអំណាចឲ្យបានច្បាស់លាស់។ជាក់ស្តែងរដ្ឋបាលរបស់សង្កាត់បាន

[11] ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០១៨-២០២២) សង្កាត់បឹងត្របែកទំព័រទី២-ទំព័រទី៣

[12] របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តន៍កម្មវិធីនយោបាយអភិវឌ្ឍន៍សង្កាត់បឹងត្របែកឆ្នាំ២០១៧-២០២១ ទំព័រទី៤

[13] ឯកសារយោងសៀវភៅ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិជ្ជការ ឆ្នាំ ២០១២

រៀបចំដោយ: khmer keep ៖ Facebook.com/khmerkeep

រៀបចំឡើង ឱ្យការគ្រប់គ្រងមានភាពងាយស្រួល និងឆាប់រហ័សនោះ ក្រុមប្រឹក្សា ដែលបានបង្កើតឡើងដោយការបោះឆ្នោត ស្របតាមច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ គឺជាតំណាងសាធារណៈជាអ្នកការពារ និងជា អ្នកបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

(មើលឧបសម្ព័ន្ធទី៣)

### ២.២.១. មេឃុំ ចៅសង្កាត់

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ជាមេឃុំ ចៅសង្កាត់ ដែលជ្រើសរើសចេញពីបេក្ខជន លើគេ បង្អស់នៃបញ្ជីបេក្ខជន ដែលបានទទួលសម្លេងឆ្នោតច្រើនជាងគេបង្អស់ៗ មេឃុំ ចៅសង្កាត់ជាតំណាងឲ្យអំណាចប្រតិបត្តិ ក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈនៅក្នុងរដ្ឋបាលឃុំ សង្កាត់។

### ២.២.២. ជំទប់ ចៅសង្កាត់រង

រដ្ឋបាលឃុំ សង្កាត់ត្រូវមានជំនួយការជា

ជំទប់ទី១: ចៅសង្កាត់រងទី១៖ ទទួលបន្ទុកលើកិច្ចការខាងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ជំទប់ទី២: ចៅសង្កាត់រងទី២៖ ទទួលបន្ទុកទៅលើកិច្ចការរដ្ឋបាល សង្គមកិច្ច សេវាសាធារណៈនិងសណ្តាប់ធ្នាប់សាធារណៈ។

មេឃុំចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមលើភារកិច្ចដែលបានកំណត់ខាងលើ។

### ២.២.៣. ស្មៀន

ឃុំ សង្កាត់មានមន្ត្រីក្របខ័ណ្ឌក្រសួងមហាផ្ទៃមួយរូបដើម្បីធ្វើជាស្មៀន។ ស្មៀននេះគឺត្រូវបាន គេតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលមានភារកិច្ចជួយការងារក្នុងឃុំ សង្កាត់ និងធានានិរន្តភាពកិច្ចការក្នុងរដ្ឋបាលឃុំ សង្កាត់។

### ២.២.៤. មេភូមិ

ដើម្បីលើកកម្ពស់ឲ្យមានប្រសិទ្ធភាពនៃការគ្រប់គ្រង់រដ្ឋបាលថ្នាក់ឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឲ្យមានមេភូមិម្នាក់ សម្រាប់ភូមិនីមួយៗចំណុះឃុំ សង្កាត់របស់ ខ្លួន។ មេភូមិនេះមិនមែនជាបុគ្គលិកនៅក្នុងក្របខ័ណ្ឌរដ្ឋទេ។ មេភូមិត្រូវរៀបចំចាត់តាំងឲ្យមានអនុ ប្រធានមួយរូប និងសមាជិកមួយរូបជាជំនួយការ។

## ២.៣. ស្ថានភាពទូទៅ

### ក. ឃុំ សង្កាត់ និងការអភិវឌ្ឍ[14]

មុខងារមួយដ៏សំខាន់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ គឺអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន។ ក្រុមប្រឹក្សាត្រូវទទួលខុសត្រូវចំពោះការរៀបចំយល់ព្រមនឹងផែនការអភិវឌ្ឍន៍ បរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច ឃុំសង្កាត់ឲ្យស្របទៅនឹងអាទិភាព អភិវឌ្ឍន៍ជាតិ។ ហើយលើសពីនេះទៅទៀតក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវតែវាយតម្លៃលើសកម្មភាពអភិវឌ្ឍន៍ដែលបានកំពុងកើតនៅក្នុងឃុំ សង្កាត់របស់ខ្លួន។ ត្រូវវាយតម្លៃសេចក្តីត្រូវការផ្សេងៗ ហើយបន្ទាប់មកទៀតត្រូវតាមដានវាយតម្លៃ រៀបចំកម្មវិធីដែលត្រូវឆ្លើយតបទៅនឹងតម្រូវការនេះ ទៅលើលទ្ធផលនៃការអនុវត្តកម្មវិធីអភិវឌ្ឍន៍របស់ខ្លួន។

សកម្មភាពរបស់អភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើទៅតាមតម្លាភាពរយៈពេល រាយការណ៍ប្រចាំឆ្នាំ។ ចំពោះឯកសារត្រូវចម្លងជូនក្រសួងមហាផ្ទៃ និងក្រសួងពាក់ព័ន្ធផ្សេងទៀត ដើម្បីតម្កល់ទុក។ រាជាកំណត់ត្រាសាធារណៈនឹងប្រគល់ឲ្យសហគមន៍ ឬអង្គការដទៃទៀតដោយ គិតជាប្រាក់។

កម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន និងវិជ្ជាការមានរៀបចំដោយមានបណ្តុំក្រសួងមួយចំនួនដែល ពាក់ព័ន្ធជាមួយ។

កម្មវិធីសម្រាប់ពង្រឹងអាជ្ញាធរមូលដ្ឋានរបស់កម្ពុជាក្នុងបរិបទនៃយុទ្ធសាស្ត្រនៃវិសហមជ្ឈការ-វិមជ្ឈការត្រូវបានអនុម័តដោយរដ្ឋាភិបាលកម្ពុជា។ កម្មវិធីនេះមានគោលបំណងធំៗបីគឺ

១-ពង្រឹងការអភិវឌ្ឍន៍នៅមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រតាមរយៈវិធីសាស្ត្រពហុវិស័យដែលរួមមានការផ្តល់សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ការជម្រុញសន្តិភាព និងបង្រួប បង្រួមផ្សះផ្សាជាតិ។

២-ស្ថាបនាសកម្មភាពអាជ្ញាធរឃុំ សង្កាត់ និងខេត្តសម្រាប់ការចាត់ចែងអភិវឌ្ឍន៍ឲ្យមាន ស្ថេរភាពតាមរយៈពិសោធន៍ជាក់ស្តែង។

៣-បង្កើតមេរៀនសម្រាប់ការអភិវឌ្ឍគោលនិយោបាយវិសហមជ្ឈការ និងវិមជ្ឈការឲ្យ ទទួលបានជោគជ័យ និងបានបង្ហាញថាវិសាលភាពដំណើរនៃការផែនការដែលផ្តល់គុណភាពដល់ ការធ្វើផែនការអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំ សង្កាត់។

### ខ. វិមជ្ឈការ និងប្រសិទ្ធភាព[15]

មូលដ្ឋាននៃអំណះអំណាងដែលបានលើកយកមកក្នុងការគាំទ្រចំពោះវិជ្ឈការពង្រឹង ប្រសិទ្ធភាពនៃការបែងចែកចំពោះធនធាន នេះជាចំណង់ចំណូលចិត្តរបស់ប្រជាពលរដ្ឋក្នុងការផ្គត់ ផ្គង់ទូទៅរបស់រដ្ឋបាលក

[14] ដកស្រង់ចេញពីសៀវភៅណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ទំព័រទី៥-១៨

[15] ដកស្រង់ចេញពីសៀវភៅណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ទំព័រទី៥-១៨

ណ្តាលចំពោះផ្លូវថ្នល់ និងការអប់រំមិនបានបំពេញចិត្តគណបក្សណាមួយ ទេ ការបែងចែកធនធានតាមរយៈវិមជ្ឈការ និងបំពេញតាមតម្រូវការនានាបានប្រសើរជាងរដ្ឋបាល កណ្តាល។ អ្នកជំនាញសេដ្ឋកិច្ចខាងវិមជ្ឈការបានអះអាងថា អំណះអំណាងប្រសិទ្ធភាពមូលដ្ឋានបានគេទិចទៀន និងរិះគន់ទៅលើចំណុចពីរយ៉ាងៈ

ទី១:មិនពាក់ព័ន្ធជាពិសេសណាមួយទៅនឹងប្រទេសកំពុងអភិវឌ្ឍន៍

ទី២:បានផ្តោតជាសំខាន់ទាំងស្រុងទៅលើប្រសិទ្ធភាព និងតម្រូវការមិនប្រងើយកន្តើយ ចំពោះប្រសិទ្ធភាពនៃការផ្គត់ផ្គង់។

ការអះអាងជាមូលដ្ឋានចំពោះការគាំទ្រនូវប្រព័ន្ធវិមជ្ឈការ ជនមានចំណង់ចំណូលចិត្តផ្សេងៈ គឺមានប្រសិទ្ធភាពច្រើនព្រោះប្រជា ការបោះឆ្នោតនៅ មូលដ្ឋានជាទូទៅត្រូវបានសម្រេចដោយពឹងផ្អែកលើមូលដ្ឋាននៃភាពស្មោះត្រង់ចំពោះគណបក្ស នយោបាយ ឬបុគ្គលណាមួយមិនមែនផ្អែកទៅលើភាពលាយបញ្ចូលគ្នានៃកញ្ចប់ពន្ធអាករនោះទេ។

ការបោះឆ្នោតនៅមូលដ្ឋាន គឺជាការសាកល្បងសម្រាប់ការបោះឆ្នោតថ្នាក់ជាតិ។ វិមជ្ឈការ គួរតែត្រូវបានទទួលនូវការត្រួតពិនិត្យអំពីឥទ្ធិពលរបស់វាទៅលើការបែងចែកឡើងវិញ(ទាំងការបែងចែកឡើងវិញជាអន្តរបុគ្គល ឬជាអន្តរយុត្តាធិការ)។ ការបែងចែកជាអន្តរបុគ្គលអាចទទួល រងឥទ្ធិពលពីវិមជ្ឈការ គឺវាអាចនាំទៅរកការអនុវត្តផ្សេងៗគ្នាចំពោះអ្នកដែលមានឋានៈស្មើគ្នានៅក្នុង ប្រទេស។ ការបែងចែកឡើងវិញជាអន្តរយុត្តាធិការអាចទទួលឥទ្ធិពលអវិជ្ជមានផងដែរពីរបបវិមជ្ឈការ។ ប្រព័ន្ធវិមជ្ឈការមួយដែលក្នុងនោះចំណាយលើពន្ធអាករទាំងឡាយដែលត្រូវបានធ្វើឡើង ដោយយុត្តាការរៀងៗខ្លួន និងមិនបានបែងចែកឡើងវិញនូវចំណូលនានាឲ្យយុត្តាធិការដទៃទៀត។ អាស្រ័យដូច្នេះគ្មានវិធានការណាមួយជាក់លាក់ដែលបានប្រមូលពន្ធ និងចំណូលផ្សេងៗអាចជម្រុញឲ្យមានសមភាពកម្រិតថ្នាក់ជាតិទាំងមូលបានឡើយ។

**គ.អភិបាលឃុំ សង្កាត់**

តម្រូវការសំខាន់ដើម្បីពង្រឹង និងបង្កើនគុណភាពសេវាសាធារណៈឲ្យបានខ្ពស់ដើម្បីផ្តល់ ឲ្យដល់ប្រជាពលរដ្ឋនៅជនបទ។ ទស្សនៈរបស់រដ្ឋាភិបាលបានចាត់ទុកថា ផ្ទេរសិទ្ធិវិមជ្ឈការរដ្ឋបាលមិនគ្រាន់តែជាធនធានមួយដើម្បីអភិវឌ្ឍន៍លើការផ្តល់សេវាសាធារណៈទៅក្នុងតំបន់ប៉ុណ្ណោះទេ ប៉ុន្តែវាអាចជួយជម្រុញឲ្យមានការអភិវឌ្ឍរួមទាំងការពង្រីកនូវលទ្ធិប្រជាធិបតេយ្យរបស់ប្រទេសដែ រ។ ទោះបីជាយ៉ាងនេះក៏ដោយនៅពេលដំណើរការវិមជ្ឈការនឹងផ្តល់នូវផលវិបាកយ៉ាងច្រើនដូចជា ការត្រួតពិនិត្យហិរញ្ញវត្ថុមិនបានគិតដល់ និងមានការកើនឡើងនូវវិសមភាពចំពោះប្រយោជន៍ សាធារណៈ។ យុទ្ធសាស្ត្រនេះត្រូវបានធ្វើឡើងដោយប្រុងប្រយ័ត្ន និងគ្រប់ជ្រុងជ្រោយ។

### ២.៣.១ សមាសភាពក្រុមប្រឹក្សាសង្កាត់បឹងត្របែក[16]

សង្កាត់បឹងត្របែកមានក្រុមប្រឹក្សាសង្កាត់ ដែលជាតំណាងប្រជាពលរដ្ឋប្រជាពលរដ្ឋក្នុងសង្កាត់ និងមានបេសកកម្មបម្រើ ផលប្រយោជន៍ទូទៅក្នុងសង្កាត់បឹងត្របែកទាំងមូល និងដោះស្រាយបញ្ហានានារបស់សង្កាត់ក្នុងរយៈពេល៥ឆ្នាំ។ ក្រុមប្រឹក្សាសង្កាត់មាន អាណត្តិ៥ឆ្នាំហើយត្រូវផុតអាណត្តិនៅពេលមានក្រុមប្រឹក្សាថ្មីចូលមកកាន់តំណែង ។

នៅក្នុងចំណោមក្រុមប្រឹក្សាឃុំទាំង២០រូបនេះ៖ មានប្រធានម្នាក់ហៅថា ប្រធានក្រុមប្រឹក្សាសង្កាត់បឹងត្របែក។ ហើយប្រធានក្រុមប្រឹក្សាឃុំនេះមានភារៈកិច្ច៖

- ធ្វើជាអធិបតីយភាពនៅក្នុងសម័យប្រជុំនានា
- ធានាអោយសម័យប្រជុំរបស់ខ្លួនតំណើការអោយបានត្រឹមត្រូវ និងតាមវិធាន និងបទបញ្ជា
- រក្សារបៀបរៀបរយ និងសណ្តាប់ធ្នាប់នៅពេលប្រជុំ។

ឧបសម្ព័ន្ធទី៥៖សមាជិកក្រុមប្រឹក្សាសង្កាត់

### ២.៣.២ តួនាទីរបស់ក្រុមប្រឹក្សាសង្កាត់[17]

តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាសង្កាត់ គឺត្រូវជំរុញយ៉ាងសកម្មនូវការអភិវឌ្ឍន៍សង្កាត់ និង លើកកំពស់សុខមាលភាពរបស់ប្រជាពលរដ្ឋនៅក្នុងសង្កាត់នោះ។ ក្រុមប្រឹក្សា ត្រូវប្រើប្រាស់ធនធានទាំងអស់ ដែលខ្លួនមានអោយបានត្រឹមត្រូវ ដើម្បីបំពីសេចក្តីត្រូវការរបស់សង្កាត់ និងប្រជាពលរដ្ឋរបស់ខ្លួន។

ក្រុមប្រឹក្សាសង្កាត់ មានភារកិច្ចបំពេញកិច្ចការនៅតាមមូលដ្ឋាន។ កិច្ចការទាំងនោះមានដូចខាងក្រោម :

- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ
- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ
- លើកទឹកចិត្តឱ្យមានការបង្កើនជាសុកភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចនិងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ
- សម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឱ្យមានការ យោគយល់អធ្យាស្រ័យ ទៅវិញទៅមក
- បំពេញកិច្ចការជាទូទៅ ដើម្បីឆ្លើយតបសេចក្តីត្រូវការ របស់ប្រជាពលរដ្ឋ។

---

[16] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២១-២០២២)សង្កាត់បឹងត្របែក ទំព័រទី៣៥-៣៦
(ដកស្រង់ចេញពីឯកសាររបស់សង្កាត់បឹងត្របែក ការអភិវឌ្ឍន៍ រយៈពេលប្រាំឆ្នាំ ២០១៨-២០២២ ទំព័រ

[17] របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាស្តីពីការអភិវឌ្ឍន៍ឃុំ-សង្កាត់តាមបែបវិមជ្ឈការរបស់និស្សិត ម៉ូវ រត្ន័ធូ សុម ពិសិដ្ឋ និងជីម សំនៀងទំព័រទី១៨

### ២.៣.៣ តួនាទីជាអ្នកតំណាងអោយ ប្រជាពលរដ្ឋ

ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ខ្លួននិងរួមចំណែកក្នុងការកសាងប្រទេសជាតិឱ្យរីកចម្រើនរុងរឿងប្រជាពលរដ្ឋគ្រប់រូបក្នុងមូលដ្ឋាន ត្រូវមានកាតព្វកិច្ចចូលរួមក្នុងការងារសំខាន់ៗ របស់ឃុំ សង្កាត់ដូចជា :

- ប្រជាពលរដ្ឋមានសិទ្ធិចូលរួមស្តាប់កិច្ចប្រជុំសាធារណៈរបស់ក្រុមប្រឹក្សាឃុំ ប៉ុន្តែពុំមានសិទ្ធិអនុម័តបានទេ។
- ប្រជាពលរដ្ឋអាចលើកសំណួរដល់មេឃុំ ចៅសង្កាត់ ឬសមាជិកក្រុមប្រឹក្សា នៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំសង្កាត់ដោយអនុលោមទៅតាមបទបញ្ជាផ្ទៃក្នុង សម្រាប់កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។
- ប្រជាពលរដ្ឋមានសិទ្ធិលើកសំណើរឬធ្វើការប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវឆ្លើយតបនឹងសំណើរ ឬ ការប្តឹងនោះជាកំហិត។
- ចំពោះសំណើរឬការប្តឹងតវ៉ាទាំងឡាយណាដែលមេឃុំ ចៅសង្កាត់មិនអាចដោះស្រាយ បានក្នុងសមត្ថកិច្ចរបស់ខ្លួន មេឃុំ ចៅសង្កាត់ត្រូវដាក់ក្នុងរបៀបវារៈអង្គប្រជុំបន្ទាប់ របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។
- មេឃុំចៅសង្កាត់ត្រូវជូនព័ត៌មានដល់ប្រជាពលរដ្ឋអំពីការ ដោះស្រាយរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ ។
- ប្រជាពលរដ្ឋមានសិទ្ធិដឹងនូវព័ត៌មានទាំងឡាយដែលទាក់ទងទៅនឹងការងារអភិវឌ្ឍន៍ ភូមិ ឃុំ។

### ២.៣.៤ តួនាទីជាអ្នកតំណាងអោយរដ្ឋ[18]

រដ្ឋបាលឃុំសង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ព្រះរាជក្រឹត្យអនុក្រឹត្យប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ ។

**មាត្រា ៣៣.**

ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវធានាផ្សព្វផ្សាយព័ត៌មានឱ្យបានទៀងទាត់ដល់ប្រជាពលរដ្ឋ ក្នុងឃុំ សង្កាត់ អំពីបញ្ហាទាំងឡាយស្របតាមសមត្ថកិច្ចរបស់ខ្លួន និងអំពីសេចក្តីសម្រេចនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

## ២.៤. អភិបាលកិច្ចល្អ គណនេយ្យភាព[19]

### ២.៤.១.អភិបាលកិច្ចល្អ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់មានគោលដៅកំណត់ការគ្រប់គ្រង ឃុំ សង្កាត់ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាតាមនយោបាយវិមជ្ឈការ។រដ្ឋបាលឃុំ សង្កាត់ មានតួនាទីជំរុញ និងគាំពារអភិបាលកិច្ចល្អដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចេរភាព សម្រាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋាននៅក្នុងឃុំសង្កាត់របស់ខ្លួនបម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋនិងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ ។

---

[18] http://ticambodia.org/library/wp-content/files_mf/1452240121roles.pdf

[19] របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាស្តីពីការអភិវឌ្ឍន៍ឃុំ-សង្កាត់តាមបែបវិមជ្ឈការរបស់និស្សិត ម៉ូវ វត្ថ៍ធូ សុម ពិសិដ្ឋ និងជីម សំនៀងទំព័រទី២០-២១

ប្រព័ន្ធនៃអភិបាលកិច្ចមូលដ្ឋានត្រូវអនុវត្តនៅថ្នាក់ឃុំ សង្កាត់ ។ អំណាចដឹកនាំ និងគ្រប់គ្រងឃុំ សង្កាត់ បានមកដោយការបោះឆ្នោតជាទូទៅ ជាសកលដោយសេរីត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ ក្នុងក្របខ័ណ្ឌឃុំ សង្កាត់នីមួយៗ ។

រដ្ឋបាលឃុំសង្កាត់មានតួនាទីពីរប្រភេទគឺតួនាទីបម្រើការងារមូលដ្ឋានសម្រាប់ផលប្រយោជន៍ឃុំ សង្កាត់ និងប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់របស់ខ្លួន និង តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ។

ឃុំ សង្កាត់ ជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងមាន បេសកកម្មបម្រើផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន ។

ក្រុមប្រឹក្សាសង្កាត់ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល អំពីការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាននានា។

### ២.៤.២ គណនេយ្យភាព

#### ក-គណនេយ្យភាពចំពោះប្រជាពលរដ្ឋ

ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋ ទាំងអស់អំពីជម្រើសជាអាទិភាព ដើម្បីធ្វើសេចក្តីសម្រេចធានាបាននូវការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សាអាចធ្វើការអង្កេតលើករណីទាំងឡាយ ដែលខ្លួនយល់ឃើញថា មានសារៈសំខាន់ដល់ ប្រជាពលរដ្ឋ ដែលខ្លួនជាតំណាង ព្រមទាំងអាចផ្សព្វផ្សាយ លទ្ធផលនៃការធ្វើអង្កេតនោះ រួចហើយត្រូវផ្តល់គោលការណ៍ណែនាំអនុវត្តដល់ គណៈអភិបាល និងអភិបាល ។

ក្រុមប្រឹក្សាត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុឱ្យមានតម្លាភាព និងមាន គណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន។

#### ខ-គណនេយ្យភាពចំពោះរាជរដ្ឋាភិបាល

ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល អំពីការប្រតិបត្តិ តាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានា។

ក្រុមប្រឹក្សាត្រូវគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន និងចំពោះរាជរដ្ឋាភិបាល ។ក្នុងតួនាទីជាតំណាងរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល អភិបាលត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួងនិងស្ថាប័ននានា ។

### ២.៤.៣ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់សង្កាត់

**មាត្រា៧៣៖** ឃុំ សង្កាត់មានធនធានហិរញ្ញវត្ថុ ថវិកានិង ទ្រព្យសម្បត្តិផ្ទាល់ ។

**មាត្រា៨២៖** ឃុំ សង្កាត់ត្រូវបង្កើតឲ្យមានប្រព័ន្ធ គ្រប់គ្រង តាមដាននិងត្រួតពិនិត្យហិរញ្ញវត្ថុរបស់ខ្លួន ។

ប្រភពចំណូលឃុំ សង្កាត់៖ ប្រភពចំណូលឃុំ សង្កាត់សំខាន់ៗមាន៣គឺ៖

- ចំណូលផ្ទាល់ ឃុំ សង្កាត់មានសិទ្ធិក្នុងការប្រមូល ចំណូលផ្ទាល់ដែលបានមកពីចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធនៅក្នុងមូលដ្ឋានឃុំ សង្កាត់ របស់ខ្លួន។
- ចំណូលពីមូលនិធិឃុំ សង្កាត់៖ ចំណូលពីមូលនិធិឃុំ សង្កាត់គឺជាចំណូលដែលបានមកពីការផ្ទេរធនធានពីមូលនិធិឃុំ សង្កាត់ឲ្យទៅឃុំ សង្កាត់នីមួយៗដែលក្នុង នោះរួមមានចំណែកសម្រាប់ចំណាយផ្នែករដ្ឋបាល និងចំណាយសម្រាប់ផ្នែកអភិវឌ្ឍន៍ឃុំ សង្កាត់ ។
- ចំណូលពីការអនុវត្តមុខងារផ្ទាល់ជាភ្នាក់ងារ៖ ចំណូល មុខងារជាភ្នាក់ងារ គឺជាចំណូលដែលបានមកពីការបំពេញភារកិច្ចដោយឃុំ សង្កាត់ជំនួសមុខឲ្យក្រសួង ស្ថាប័ន ឬអង្គភាពនានាទៅតាមការព្រមព្រៀងគ្នា ។

ថវិកាឃុំ សង្កាត់៖ ថវិកាគឺជាលិខិតគតិយុត្តិដែលក្រុមប្រឹក្សាឃុំ សង្កាត់មានសិទ្ធិពេញលេញក្នុងការគ្រោងចំណូល ចំណាយ និងអនុវត្តចំណូលចំណាយតាមថវិកាគ្រោង ។

### ២.៤.៤. ប្រភពចំណូលសំខាន់ៗរបស់សង្កាត់

ប្រភពចំណូលរបស់ឃុំ សង្កាត់ មាន៣សំខាន់ៗ គឺ ចំណូលផ្ទាល់ ចំណូលពីមូលនិធិឃុំ សង្កាត់ ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ ។

- ចំណូលផ្ទាល់ឃុំសង្កាត់ មានសិទ្ធិទទួលចំណូលផ្ទាល់ដែលបានមកពីចំណូលសារពើពន្ធ ឬមិនមែនសារពើពន្ធ ឬកម្រៃផ្សេងៗទៀត។ បច្ចុប្បន្ន ចំណូលប្រភេទនេះពុំមានច្បាប់អនុញ្ញាតអោយអនុវត្តនៅឡើយ ព្រោះមិនទាន់មានច្បាប់ ស្តីពីការប្រមូលពន្ធប្រភេទនេះ ។
- ចំណូលបានមកពីមូលនិធិ ឃុំសង្កាត់ នេះគឺជាចំណូល ដែលបានមកពីការផ្ទេរធនធានពីមូលនិធិឃុំ សង្កាត់ទៅអោយឃុំ សង្កាត់នីមួយៗ ដែល ក្នុងនោះមានចំណាយសម្រាប់ផ្នែករដ្ឋបាល និងចំណាយសម្រាប់ការអភិវឌ្ឍឃុំ សង្កាត់ ។
- ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ គឺជាចំណូលដែលបានមកពីការបំពេញភារកិច្ច របស់ឃុំ សង្កាត់ជំនួសមុខអោយក្រសួង ស្ថាប័ន ឬអង្គភាពនានារបស់រដ្ឋ ទៅតាម ការព្រមព្រៀងគ្នា ។

ក្រៅពីប្រភពចំណូលសំខាន់ៗទាំង៣ខាងលើនៅមានប្រភពផ្សេងៗទៀតដូចជា ចំណូលបានមកពីការចូលរួមចំណែករបស់ប្រជាពលរដ្ឋ ចំណូលបានមកពីអង្គការក្រៅរដ្ឋាភិបាល និងកម្មវិធីផ្សេងៗឃុំ សង្កាត់ ត្រូវទទួលខុសត្រូវរាល់ការចំណាយរបស់ខ្លួនអោយបានម៉ត់ចត់ តម្លាភាព សន្សំសំចៃ និងមានគុណភាពខ្ពស់។

### ២.៤.៥. ការរៀបចំថវិកា[20]

គម្រោងថវិកាត្រូវរៀបចំឡើងក្រោមការទទួលខុសត្រូវរបស់មេឃុំចៅសង្កាត់ និងដោយមានជំនួយការពីគណៈកម្មាធិការកសាងផែនការនិងថវិកាឃុំសង្កាត់ហើយត្រូវបញ្ជូនទៅក្រុមប្រឹក្សាឃុំសង្កាត់ពិនិត្យ និង អនុម័ត ។ ការអនុម័តត្រូវធ្វើឡើងតាមផ្នែក និង ប្រភេទនីមួយៗនៃគម្រោងថវិកា ។

មេឃុំចៅសង្កាត់ត្រូវធានាឲ្យមានការចូលរួមពីសាធារណជនមូលដ្ឋានក្នុងដំណើរការរៀបចំ ថវិកាតាមរយៈវិធានការទាំងឡាយដូចខាងក្រោមនេះ ៖

- គម្រោងថវិកាត្រូវតែប្រកាសផ្សាយជាសាធារណៈយ៉ាងតិច២សប្តាហ៍មុនពេលកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ. សង្កាត់
- អង្គប្រជុំរបស់គណៈកម្មាធិការកសាងផែនការនិងថវិកាត្រូវបើកចំហដល់សាធារណជនដែលចាប់អារម្មណ៍លើការពិនិត្យគម្រោងថវិកានេះ
- ប្រជាពលរដ្ឋត្រូវតែបានផ្តល់កាលានុវត្តភាពក្នុងការចូលរួមសម័យប្រជុំរបស់ក្រុមប្រឹក្សាឃុំសង្កាត់ដែលសម្រេចលើគម្រោងថវិកា
- ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបង្កើតនូវយន្តការផ្សេងៗដើម្បីជម្រុញឲ្យមានការចូលរួមពីសាធារណជនលើ កិច្ចការមូលដ្ឋាន ។
- គម្រោងថវិកានោះត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធដូចខាងក្រោមនេះ ៖
- របាយការណ៍សង្ខេបស្តីពីមូលដ្ឋានក្នុងការរៀបចំចំណូលនិងចំណាយព្រមទាំងកម្រិតចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការរៀបចំថវិកា
- របាយការណ៍ស្តីពីការអនុវត្តន៍ថវិកានៃឆ្នាំដំណើរការ
- តារាងសង្ខេបនៃការវិនិយោគហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដែលបានបញ្ជាក់ក្នុងផែនការអភិវឌ្ឍឃុំសង្កាត់ ប្រសិនបើមាន
- កំណត់ហេតុស្តីពីកិច្ចប្រជុំអនុម័តលើគម្រោងថវិការបស់ក្រុមប្រឹក្សាឃុំសង្កាត់ ។

### ២.៤.៦. ការអនុវត្តថវិការឃុំ សង្កាត់[21]

ថវិកាឃុំសង្កាត់អាចនឹងត្រូវបានកែតម្រូវក្នុងអំឡុងពេលឆ្នាំថវិកាដើម្បីឆ្លើយតប ទៅ នឹង ការប្រែប្រួលនៃល័ក្ខខ័ណ្ឌសេដ្ឋកិច្ច ឬ ហិរញ្ញវត្ថុដែលជះឥទ្ធិពលទៅលើការព្យាករណ៍ដំបូងនៃចំណូលនិង ចំណាយ។ ការកែ

---

[20] (ដកស្រង់ ពី អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ មាត្រា11 មាត្រា12 មាត្រា13 ក្នុងទំព័រទី4 និង ទី5)

[21] (ដកស្រង់ ពី អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ មាត្រា 20 មាត្រា22 ក្នុងទំព័រទី 7និង ទី 8)
មាត្រាទី៣ អនុក្រឹត្យលេខ១៩ អនុក្រម. មូលនិធិឃុំ-សង្កាត់

តម្រូវថវិកាត្រូវរៀបចំពិនិត្យអនុម័តនិងបញ្ជាក់ទទួលស្គាល់តាមនីតិវិធី ។ប្រសិនបើ គោលបំណងនៃការកែតម្រូវថវិកាគ្រាន់តែជាការវិភាជន៍ធនធានឡើងវិញក្នុងប្រភេទចំណាយតែមួយ ដោយមិនធ្វើឲ្យប្រែប្រួលចំនួនទឹកប្រាក់នៃប្រភេទចំណាយឬមិនធ្វើឲ្យប្រែប្រួលប្រភេទគម្រោងវិនិយោគ នៅក្នុងថវិកាដំបូងនោះពុំចាំបាច់សុំការបញ្ជាក់ទទួលស្គាល់ឡើងវិញពីអភិបាលខេត្តក្រុងទេ។ក្នុងករណីនេះមេឃុំចៅសង្កាត់ត្រូវជូនដំណឹងដល់អភិបាលខេត្តក្រុងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរតនាគារខេត្ត ក្រុងអំពីការប្រែប្រួលធនធានវិភាជន៍ឡើងវិញមិនឲ្យយឺតជាង៥ថ្ងៃបន្ទាប់ពីការពិភាក្សាសម្រេចរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ។ ឥណទានថវិកានៃប្រភេទណាមិនបានគ្រោងទុកមិនត្រូវលើស៣%នៃថវិកាសរុប។ខ្ទង់ថវិកានៃចំណាយមិនបានគ្រោងទុកអាចត្រូវបានប្រើប្រាស់សម្រាប់ធានាចំពោះការចំណាយទាំងឡាយណាដែលការវិភាជន៍មិនត្រូវបានកំណត់ជាក់លាក់នៅពេលឥណទានត្រូវបានអនុម័តឬសម្រាប់ឥណទានបំពេញបន្ថែមជាគុណប្រយោជន៍ដល់ប្រភេទចំណាយផ្សេងៗទៀតរបស់ឃុំសង្កាត់។ មេឃុំចៅសង្កាត់ត្រូវស្នើសុំការអនុម័តពីក្រុមប្រឹក្សាឃុំសង្កាត់មុនពេលសម្រេចចិត្តលើការប្រើប្រាស់ឥណទានថវិកាចំណាយមិនបានគ្រោងទុក។ មេឃុំចៅសង្កាត់ត្រូវដាក់របាយការណ៍បិទបញ្ជីជូនក្រុមប្រឹក្សាឃុំសង្កាត់ដើម្បីពិនិត្យអនុម័តបន្ទាប់ពីការពិភាក្សាក្រុមប្រឹក្សាឃុំសង្កាត់ត្រូវអនុម័តដោយបោះឆ្នោតលើសេចក្ដីសម្រេចស្ដីពីការបិទបញ្ជីថវិកា ។ សេចក្ដីសម្រេចស្ដីពីការបិទបញ្ជីថវិកាត្រូវ ៖

១- បញ្ជាក់នូវចំណូលចំណាយជាក់ស្ដែងដែលសម្រេចបានក្នុងឆ្នាំថវិកា

២- លុបចោលឥណទានថវិកាដែលមិនបានប្រើប្រាស់

៣- អនុញ្ញាតឲ្យផ្ទេរលទ្ធផលនៃឆ្នាំថវិកាទៅគណនីមូលនិធិបម្រុង ។

បន្ទាប់ពីបានអនុម័តរួចយ៉ាងយូរ៧ថ្ងៃប្រធានក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបញ្ជូន"សេចក្ដីសម្រេច ស្ដីពីការបិទបញ្ជីថវិកា" ទៅអភិបាលខេត្តក្រុងដើម្បីពិនិត្យបញ្ជាក់ទទួលស្គាល់ដោយភ្ជាប់ជាមួយនូវ ៖

- របាយការណ៍បិទបញ្ជីគណនេយ្យ
- របាយការណ៍ស្ដីពីសកម្មភាពទូទៅនៃឃុំសង្កាត់
- កំណត់ហេតុនៃការពិភាក្សាអនុម័តរបស់ក្រុមប្រឹក្សាឃុំសង្កាត់។

### ២.៤.៧. ការចូលរួមរបស់ប្រជាពលរដ្ឋ

ការចូលរួមគឺជាស្នូលវិមជ្ឈការ លិទ្ធិប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ។ ប្រសិនបើ គ្មានការចូលរួមពីសំណាក់ប្រជាពលរដ្ឋទេនោះ វិមជ្ឈការមិនអាចដំណើរការបានទេ។ ការចូលរួមរបស់ពួកគាត់ គឺផ្ដល់ឱកាសក្នុងការ គ្រប់គ្រងជីវភាពរស់នៅ និងការកំណត់អនាគតរបស់ខ្លួនផ្ទាល់ ។ ពួកគាត់មានឱកាសសំដែងមតិអោយអ្នកដទៃដឹងឮ ហើយការចូលរួមចំនែករបស់ពួកគាត់គឺមានតម្លៃទាំងអស់ ។ បើពួកគាត់ មិនចូលរួមក្នុងកម្មវិធីអភិវឌ្ឍន៍របស់ក្រុម ប្រឹក្សាឃុំទេ ពួកគាត់នឹងមិនបានទទួលផលប្រយោជន៍ពីកម្មវិធីនោះឡើយ ហើយកម្មវិធីនេះមិនអាច

ដំណើរការបាននៅក្នុងឃុំបានទេ។ ដូចនេះប្រជាជនដែលបានបោះឆ្នោត ត្រូវចូលរួមក្នុងការធ្វើសេចក្តីសំរេចចិត្ត របស់ក្រុមប្រឹក្សា ឃុំទាំងអស់គ្នាដើម្បីអភិវឌ្ឍន៍ឃុំរបស់ខ្លួន ព្រោះរាល់កម្មវិធីទាំងអស់វាជះឥទ្ធិពលដល់ជីវភាព របស់ពួកគេ។

នៅក្នុងសង្កាត់ បើតាមប្រសាសន៍របស់លោកចៅសង្កាត់ ក៏ដូចជាក្រុមប្រឹក្សាឃុំបានលើកឡើងថា ប្រជាជននៅក្នុងមូលដ្ឋានបានចូលរួមយ៉ាងសកម្មលើផែនការអភិវឌ្ឍ និងកិច្ចប្រជុំផ្សេងៗរបស់ឃុំ។ រាល់សកម្មភាពដែលឃុំបានដាក់ចេញ គឺសុទ្ធសឹងតែជាសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ហើយផ្អែកអាទិភាព គឺជា ការកំណត់នូវសេចក្តីត្រូវការបន្ទាន់ជាសមូហភាពរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានផ្ទាល់ ។

ការឆ្លើយតបយ៉ាងស្រដៀងគ្នា ទៅនឹងមតិរបស់ក្រុមប្រឹក្សាខាងលើរបស់ប្រជាជននៅក្នុងភូមិទាំង៨ របស់ សង្កាត់បឹងត្របែក បានបង្ហាញថា ពួកគាត់ពិតជាបានចូលរួមក្នុងសកម្មភាពផ្សេងៗជាមួយក្រុមប្រឹក្សាឃុំ សង្កាត់មែន ដូចជា ចូលរួមប្រជុំលើផែនការអភិវឌ្ឍ ការចូលរួមបើកការដ្ឋាន និងសកម្មភាពផ្សេងៗទៀតរបស់ឃុំ ប៉ុន្តែប្រជាជនមួយ ចំនួនមិនបានចូលរួមនៅក្នុងសកម្មភាពរបស់សង្កាត់ទេ ដោយសារជាប់រវល់នៅក្នុងការប្រកបរបរប្រចាំថ្ងៃ តែពួកគាត់ បានបង្ហាញនូវទឹកចិត្តសប្បាយរីករាយ និងលើកយោបល់បន្ថែមទៀតថា ថ្វីត្បិតតែពួកគាត់ មិនបានចូលរួមជាមួយ សកម្មភាពរបស់សង្កាត់ពិតមែនតែពួកគាត់ពេញចិត្តនូវសមិទ្ធិផលទាំងឡាយដែលកើតឡើងនៅក្នុងសង្កាត់របស់គាត់ណាស់ ពិសេស គឺមានការយកចិត្តទុកដាក់ពីសំណាក់ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ ហើយសំណូមពរអោយក្រុមប្រឹក្សាបន្តអភិវឌ្ឍន៍អោយកាន់តែខ្លាំងក្លាជាងនេះទៀត ដើម្បីអោយប្រជាពលរដ្ឋក្នុងមជ្ឈដ្ឋានទាំងមូលជៀសផុតអោយបាននូវការលំបាកគ្រប់បែបយ៉ាងពិសេសភាពក្រីក្រ។

## ២.៥. ក្រុមប្រឹក្សាសង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាអ្នកធ្វើសេចក្តីសម្រេច។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រជុំដើម្បីធ្វើការសម្រេចលើការងារដូចខាងក្រោម៖

- អនុម័តផែនការអភិវឌ្ឍឃុំ សង្កាត់ និងរាល់ការកែតម្រូវផែនការអភិវឌ្ឍឃុំ សង្កាត់
- អនុម័តកម្មវិធីវិនិយោគ និងរាល់ការកែតម្រូវកម្មវិធីវិនិយោគឃុំ សង្កាត់
- អនុម័តសេចក្តីព្រាងគម្រោងថវិកាឃុំ សង្កាត់ និងរាល់ការកែតម្រូវគម្រោងថវិកាឃុំ សង្កាត់
- ធ្វើការតាមដានដំណើរការនៃការរៀបចំគម្រោង
- បង្កើតយន្តការដើម្បីធានាការចូលរួមរបស់សហគមន៍ឲ្យបានច្រើន ក្នុងការរៀបចំ និងអនុវត្តគម្រោង។

### ២.៥.១.គណៈកម្មាធិការកសាងផែនការ និងថវិកា

គណៈកម្មាធិការកសាងផែនការនិងថវិកាផ្តល់យោបល់ និងជួយមេឃុំចៅសង្កាត់ក្នុងការធ្វើសេចក្តីព្រាងផែនការអភិវឌ្ឍន៍កម្មវិធីវិនិយោគ និងគម្រោងថវិកាដើម្បីដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់អនុម័ត។ ក្នុងការអនុវត្តគម្រោងគណៈកម្មាធិការកសាងផែនការនិងថវិកាអាចជួយដល់មេឃុំចៅសង្កាត់ក្នុងការប្រមូលទុនចូលរួមរបស់មូលដ្ឋាន។

**មេឃុំ ចៅសង្កាត់**

មេឃុំ ចៅសង្កាត់ ទទួលខុសត្រូវក្នុងការគ្រប់គ្រងការអនុវត្តគម្រោងដែលមាននៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ និងគម្រោងថវិកាឃុំ សង្កាត់។

- នៅក្នុងដំណាក់កាលនៃការរៀបចំគម្រោង មេឃុំ ចៅសង្កាត់ទទួលខុសត្រូវក្នុងការគ្រប់គ្រងការសិក្សាគម្រោង និងសម្របសម្រួលការងារជាមួយអ្នកពាក់ព័ន្ធទាំងអស់។
- នៅពេលបញ្ចប់ការសិក្សាគម្រោង មេឃុំ ចៅសង្កាត់ត្រូវផ្ញើទម្រង់ព័ត៌មានគម្រោង និងឯកសារពាក់ ព័ន្ធទាំងអស់ទៅអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុងដើម្បីពិនិត្យ។

### ២.៥.២.គណៈកម្មាធិការគ្រប់គ្រងគម្រោង[22]

មេឃុំ ចៅសង្កាត់ត្រូវបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងមួយសម្រាប់គម្រោងឃុំ សង្កាត់នីមួយៗ តាមរយៈសេចក្តីសម្រេចរបស់ឃុំ សង្កាត់។ តួនាទីរបស់គណៈកម្មការគ្រប់គ្រងគម្រោង គឺដើម្បីជួយ និងផ្តល់យោបល់ដល់មេឃុំ ចៅសង្កាត់និងចូលរួមក្នុងការរៀបចំគម្រោង។

មេឃុំ ចៅសង្កាត់អាចអញ្ជើញបុគ្គលិកមូលដ្ឋានពីភ្នាក់ងារ ឬតំណាងអង្គការសហគមន៍មូលដ្ឋានដែលពាក់ព័ន្ធនឹងគម្រោងមួយចំនួន ដូចជាគម្រោងសាលារៀន មណ្ឌលសុខភាព ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ឬគម្រោងសេវាកម្មនានា ដើម្បីចូលរួមកិច្ចប្រជុំគណៈកម្មការគ្រប់គ្រងគម្រោងក្នុងនាមជាអ្នកសង្កេតការ។ អ្នកជំនួយបច្ចេកទេស និងអ្នកសម្របសម្រួលស្រុក ខណ្ឌ ចូលរួមការប្រជុំរបស់គណៈកម្មាការគ្រប់គ្រងគម្រោងក្នុងនាមជាអ្នកសង្កេតការ។

នៅក្នុងដំណាក់កាលរៀបចំគម្រោង គណៈកម្មាធិការគ្រប់គ្រងគម្រោងនឹងរៀបចំប្រជុំ ដើម្បី៖

- រៀបចំតួនាទី និងការទទួលខុសត្រូវ សម្រាប់ការរៀបចំគម្រោង
- ឯកភាពទៅលើគ្រោងការគម្រោង។

កំណត់ហេតុនៃការប្រជុំនេះ ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាឃុំ សង្កាត់។

---

[22] ប្រភព៖សៀវភៅណែនាំស្តីពី ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

ក្រៅពីការប្រជុំនេះ សមាជិកគណៈកម្មការគ្រប់គ្រងគម្រោង ត្រូវអនុវត្តតួនាទីរបស់ខ្លួនដែលបានកំណត់តំណាង ឲ្យមេឃុំ ចៅសង្កាត់។

ប្រភពៈសៀវភៅណែនាំស្តីពី ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

### ២.៥.៣.ការកសាងផែនការនៃការអភិវឌ្ឍឃុំ-សង្កាត់[23]

#### ក. ការរៀបចំយន្តការ

មេឃុំឬចៅសង្កាត់ជាអ្នកទទួលខុសត្រូវខាងផ្នែកសម្របសម្រួលការងាររៀបចំផែនការអភិវឌ្ឍឃុំ-សង្កាត់ ព្រមទាំងពិនិត្យមើលនឹងកែតម្រូវឡើងវិញជារៀងរាល់ឆ្នាំ តាមរយៈការកសាងកម្មវិធីវិនិយោគរបស់ឃុំ-សង្កាត់ ។ ហើយ បន្ទាប់មកត្រូវដាក់ជូនសេចក្តីព្រាងផែនការអភិវឌ្ឍឃុំ-សង្កាត់ និងកម្មវិធីវិនិយោគរបស់ឃុំ-សង្កាត់ ទៅក្រុមប្រឹក្សាដើម្បីអនុម័ត ។

ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវទទួលខុសត្រូវលើសេចក្តី

អនុម័តផែនការនេះ នៅឆ្នាំទី១នៃអាណត្តិរបស់ខ្លួន

- អនុម័តរាល់ការកែតម្រូវផែនការអភិវឌ្ឍឃុំ-សង្កាត់ ក្នុងករណីចាំបាច់
- អនុម័តកម្មវិធីវិនិយោគនៅក្នុងឃុំ-សង្កាត់
- ត្រួតពិនិត្យ តាមដាន និង វាយតម្លៃពីលទ្ធផល និងឥទ្ធិពលនៃការអនុវត្តន៍ផែនការ ។

តាមរយៈការធ្វើប្រតិភូកម្មពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្ត-ក្រុងត្រូវបង្កើតប្រព័ន្ធគាំទ្រការកសាង និងអនុវត្តន៍ផែនការអភិវឌ្ឍឃុំ-សង្កាត់ ដែលជាផ្នែកមួយនៃការរៀបចំជាទូទៅរបស់រាជរដ្ឋាភិបាល សម្រាប់គាំទ្រ និងត្រួតពិនិត្យណែនាំដល់ក្រុមប្រឹក្សាឃុំ-សង្កាត់។ ប្រព័ន្ធនេះត្រូវមានសមាសភាព ដូចខាងក្រោម :

មន្ទីរផែនការខេត្ត-ក្រុង ទទួលខុសត្រូវ :

១. ក្នុងការពិនិត្យផ្នែកបច្ចេកទេសលើផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរបស់ឃុំ-សង្កាត់

២. ផ្តល់ការណែនាំផ្នែកនីតិសាស្ត្រ ដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ លើរាល់ទិដ្ឋភាពនៃដំណើរការ កសាងផែនការ និងកម្មវិធីវិនិយោគ

៣. ផ្តល់ការបណ្តុះបណ្តាល និងការណែនាំបច្ចេកទេសកសាងផែនការ និងកម្មវិធីវិនិយោគដល់កម្មវិធីបណ្តុះបណ្តាលទាំងអស់

៤. បណ្តុះបណ្តាលគ្រូ ក្នុងបច្ចេកទេសផែនការដល់បុគ្គលិករដ្ឋបាលថ្នាក់ខេត្ត-ក្រុង ស្រុក-ខណ្ឌ បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល និងអ្នកផ្តល់សេវាកម្មនានា

[23] ប្រកាសអន្តរក្រសួង ០៩៨. ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់, ប្រការទី៦ ជំពូកទី២

៥. ផ្តល់ការបណ្តុះបណ្តាលចំណេះដឹង អំពីការងារកសាងផែនការ និងកម្មវិធីវិនិយោគ ដល់សមាជិកក្រុមប្រឹក្សា ស្មៀន និងមន្ត្រីនានារបស់ក្រុមប្រឹក្សា ព្រមទាំងបុគ្គលសំខាន់ៗ ។

អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត-ក្រុង ទទួលខុសត្រូវ :

១. ជាខ្សែរយៈទំនាក់ទំនងទោលរវាងក្រុមប្រឹក្សាឃុំ-សង្កាត់ជាមួយរដ្ឋបាលថ្នាក់ ខេត្ត-ក្រុង

២. ណែនាំក្រុមប្រឹក្សាពីការងារដែលត្រូវធ្វើដើម្បីអនុវត្ត

៣. ជួយក្រុមប្រឹក្សា ក្នុងការរៀបចំ ការអនុវត្តន៍ ការតាមដាន និងវាយតម្លៃ លទ្ធផល និងផល ប៉ះពាល់ដល់ការអនុវត្តផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ ឃុំ-សង្កាត់ ។

មន្ទីរជំនាញផ្សេងទៀតនៅថ្នាក់ខេត្ត-ក្រុង ដែលជ្រើសតាំងដោយអភិបាលខេត្ត-ក្រុង ទទួលខុសត្រូវ ក្នុងការផ្តល់ជំនួយបច្ចេកទេសដល់ការរៀបចំបង្កើត និងអនុវត្តគម្រោងនានារបស់ក្រុម ប្រឹក្សា។

គ្រប់អង្គការសង្គមស៊ីវិល អាចចូលរួមក្នុងការរៀបចំផែនការអភិវឌ្ឍឃុំ-សង្កាត់ និងកម្មវិធីវិនិយោគរបស់ឃុំ - សង្កាត់ ហើយនិងទទួលខុសត្រូវ :

១. ចូលរួមជាតំណាងអោយផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធណាមួយ ជាក់លាក់ដូចជា ស្ត្រី យុវជនជនក្រីក្រ ជនជាតិភាគតិច

២. ចូលរួមចំណែកផ្តល់ចំណេះដឹង និងគំនិតផ្សេងៗក្នុងការរៀបចំផែនការអភិវឌ្ឍ។

**ខ.ដំណើរការកសាងផែនការឃុំ សង្កាត់**[24]

ក្រុមប្រឹក្សាឃុំ-សង្កាត់នីមួយៗ ត្រូវអនុវត្តដំណើរការកសាងនិងអនុម័តផែនការអភិវឌ្ឍឃុំ-សង្កាត់ និងកម្មវិធីវិនិយោគឃុំ-សង្កាត់តាមដំណាក់កាលទាំង៥ ដូចតទៅ :

១. ធ្វើការវិភាគទិន្នន័យព័ត៌មាន

២. ធ្វើការកំណត់យុទ្ធសាស្ត្រ

៣. ធ្វើការរៀបចំបង្កើតគម្រោង

៤. ធ្វើការរៀបចំបង្កើតកម្មវិធី

៥. ធ្វើការអនុម័តផែនការ ។

អាស្រ័យទៅតាមកាលៈទេសៈជាក់ស្តែង លទ្ធភាពធនធានមនុស្ស និងបច្ចេកទេសដែលមានក្រុមប្រឹក្សាឃុំ-សង្កាត់អាចជ្រើសរើសវិធីសាស្ត្រ និងកម្រិតបច្ចេកទេសផ្សេងៗគ្នា ក្នុងដំណាក់កាលទាំងប្រាំនេះ ដើម្បីធ្វើការរៀបចំកសាងផែនការអភិវឌ្ឍឃុំ-សង្កាត់របស់ខ្លួន។

---

[24] ប្រកាសអន្តរក្រសួង ០៩៨. ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់, ប្រការទី៦ ជំពូកទី២

**គ. ការអនុវត្តន៍ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់**[25]

ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវបង្កើតយន្តការសមស្របនានាដើម្បីសម្របសម្រួលរាល់ការចូលរួមពាក់ព័ន្ធរបស់អ្នកទទួលផលផ្ទាល់នៅក្នុងគម្រោងលំអិតនានានិងត្រួតពិនិត្យ ណែនាំការអនុវត្តគម្រោងទាំងអស់ដែលមានក្នុងផែនការការអភិវឌ្ឍន៍ឃុំ-សង្កាត់និងកម្មវិធីវិនិយោគឃុំ-សង្កាត់។មេឃុំ-ចៅសង្កាត់ត្រូវ ពិនិត្យមើលលើលទ្ធកម្មការងារសំភារៈបរិក្ខារនិងសេវាកម្មដើម្បីអនុវត្តគម្រោងទាំងអស់ និងសកម្មភាពនានាអោយស្របតាមបទបញ្ញត្តិទាំងឡាយស្តីពីលទ្ធកម្មរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់ឃុំ-សង្កាត់ ។

មុនពេលធ្វើលទ្ធកម្មការងារទំនិញនិងសេវាកម្មសម្រាប់អនុវត្តគម្រោងណាមួយរបស់ឃុំ-សង្កាត់ត្រូវស្វែង រកការបញ្ជាក់ផ្នែកបច្ចេកទេសពីមន្ទីរជំនាញពាក់ព័ន្ធជុំវិញខេត្ត-ក្រុងតាមរយៈអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត-ក្រុង។ ក្នុងរយៈពេល១៥ថ្ងៃ គិតពីថ្ងៃដែលបានដាក់ពាក្យសុំទៅអង្គភាពពាក់ព័ន្ធបើអង្គភាពនោះគ្មានការបញ្ជាក់អ្វីជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ-សង្កាត់វិញទេនោះខ្លឹមសារនៃពាក្យសុំត្រូវចាត់ទុកថាទទួលបានការបញ្ជាក់ឯកភាព ផ្នែកបច្ចេកទេសរួចរាល់ហើយ ។

**ឃ.ការតាមដាន និងវាយតម្លៃលើផែនការអភិវឌ្ឍន៍ឃុំ សង្កាត់**

ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវធ្វើការតាមដានការវិវត្តនៃការអនុវត្តផែនការអភិវឌ្ឍឃុំ-សង្កាត់និងកម្មវិធីវិនិយោគឃុំ-សង្កាត់។ ប្រការនេះរួមបញ្ចូលសកម្មភាពទាំងឡាយណា ដែលបានអនុវត្តនៅក្នុងដែនដីឃុំ- សង្កាត់ដោយស្ថាប័នរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិនានា និងផ្នែកឯកជន។

ការតាមដានអនុវត្តដោយក្រុមប្រឹក្សាឃុំ-សង្កាត់ មិនត្រូវបង្កការរាំងស្ទះដល់សិទ្ធិរបស់អង្គភាពពាក់ព័ន្ធដែលត្រូវធ្វើការតាមដាន និងវាយតម្លៃសកម្មភាពនានា ទាក់ទងទៅនឹងគម្រោង ដែលគេកំពុងគាំទ្រនៅក្នុងឃុំ-សង្កាត់នោះឡើយ ។ ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវធានាអោយមានអន្តរាគមន៍យ៉ាងឆាប់រហ័ស ដើម្បីដោះស្រាយការលំបាក ឬ បញ្ហានានាដែលកើតមានឡើងជាយថាហេតុក្នុងអំឡុងពេលអនុវត្តផែនការអភិវឌ្ឍឃុំ-សង្កាត់ និងកម្មវិធីវិនិយោគ ។

ការវាយតម្លៃគ្រប់ជ្រុងទៅលើលទ្ធផល និងផលប៉ះពាល់នៃការអនុវត្តផែនការ ត្រូវរៀបចំឡើងក្នុង អំឡុងពេល៦ខែ មុនផុតអាណត្តិរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់។ ក្រសួងមហាផ្ទៃ និងក្រសួងផែនការត្រូវរួមគ្នារៀបចំចេញសេចក្តីណែនាំលំអិតស្តីពី វិសាលភាព និងទម្រង់បែបបទសំរាប់ការងារវាយតម្លៃនេះ ។

[25] 90 ប្រកាសអន្តរក្រសួង ០៩៨. ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់, ប្រការទី២២

**ខ.ការឆ្លើយតបរបស់ផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់**[26]

ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវរៀបចំនិងអនុវត្តន៍នូវផែនការឃុំ-សង្កាត់ ហើយផែនការនេះត្រូវបង្ហាញអំពីកម្មវិធី និង សកម្មភាពផ្សេងៗដែលឃុំ-សង្កាត់មានបំណងអនុវត្តន៍នៅពេលខាងមុខ។ កម្មវិធីនិងសកម្មភាពទាំងនេះ ត្រូវឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ប្រជាជន។ ផែនការអភិវឌ្ឍនេះ ក៏ត្រូវស្របទៅតាមផែនការអភិវឌ្ឍ។

សេដ្ឋកិច្ចនិងសង្គមកិច្ចរបស់ជាតិ។ មានដំណើរការនិងវិធានការណ៍ជាច្រើននៅក្នុងការរៀបចំផែនការអភិវឌ្ឍ ឃុំ-សង្កាត់ដូចជា ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវវាយតម្លៃលើកម្រិតនៃការអភិវឌ្ឍនៅក្នុងភូមិឃុំរបស់ខ្លួនដើម្បី បានស្គាល់ពីអ្វីដែលជាសេចក្តីត្រូវការចាំបាច់បំផុតរបស់ប្រជារាស្ត្រ ហើយរៀបចំកម្មវិធីអភិវឌ្ឍន៍ ដែលឆ្លើយតបទៅ សេចក្តីត្រូវការទាំងនោះ។ ផលប្រយោជន៍របស់បុរសនិងស្ត្រី ជាពិសេសជនក្រីក្រ ក៏ត្រូវលើកយកមកពិចារណា ផងដែរ។ បន្ទាប់មក ត្រូវអនុវត្តន៍ផែនការនោះ អោយស្របទៅតាមធនធានដែលក្រុមប្រឹក្សាឃុំ-សង្កាត់មាន។ បុរសនិងស្ត្រី ត្រូវទទួលផលប្រយោជន៍ស្មើៗគ្នាពីកម្មវិធីអភិវឌ្ឍន៍នេះ។ លទ្ធផលនៃការអនុវត្ត ត្រូវតែរាយការណ៍ ជូនទៅដល់ប្រជាពលរដ្ឋ ។

ប្រជាពលរដ្ឋមានឱកាសសំដែងមតិនិងឆន្ទៈដូច្នេះគាត់អាចចូលរួមដោយផ្ទាល់នៅក្នុងការធ្វើសេចក្តី សម្រេចចិត្ត ទៅលើអ្វីដែលមានការប៉ះពាល់លើជីវភាពរស់នៅរបស់ពួកគាត់។ ទោះជាយ៉ាងណាក៏ដោយ ប្រជាជន ក្រីក្រអាចមានការភ័យខ្លាចនៅក្នុងការលើកឡើងពីសេចក្តីត្រូវការរបស់ខ្លួន។ គាត់ប្រហែល ជាមិនធ្លាប់និយាយអ្វីដែលតំណាងអោយផលប្រយោជន៍របស់គាត់ទេ។ ដូច្នេះ៖ ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវទទួលយកការបណ្តុះបណ្តាល ពីរបៀបស្វែងរកសេចក្តីត្រូវការរបស់ជនក្រីក្រ និងពីរបៀបផ្តល់សេវាទៅដល់ជនក្រីក្រ។ ក្រុមប្រឹក្សាត្រូវដឹងពី របៀបបង្កើតទំនាក់ទំនងជាមួយក្រុមអភិវឌ្ឍន៍នៅមូលដ្ឋាន និងអង្គការសង្គមស៊ីវិលដែលកំពុងធ្វើការងារជាមួយ ប្រជាពលរដ្ឋផ្ទាល់ ជាពិសេសប្រជាជនក្រីក្រ។ អង្គការសង្គមស៊ីវិល ត្រូវដឹងពីរបៀបទាក់ទាញរកផលប្រយោជន៍ ដែលបម្រើអោយជនក្រីក្រ។ ហើយ ជនក្រីក្រខ្លួនឯងផ្ទាល់ ក៏ត្រូវទទួលយកការបណ្តុះបណ្តាល និងលើកទឹកចិត្ត អោយបង្ហាញពីសេចក្តីត្រូវការ និងផលប្រយោជន៍របស់ខ្លួនផងដែរ ។

[26] ប្រកាសអន្តរក្រសួង ០៩៨. ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់, ប្រការទី២៥

# ជំពូកទី៣
# ស្ថានភាពទូទៅជុំវិញការអភិវឌ្ឍក្នុង
# សង្កាត់បឹងត្របែក

# ជំពូកទី៣

# ស្ថានភាពទូទៅជុំវិញការអភិវឌ្ឍក្នុងសង្កាត់បឹងត្របែក

## ៣.១.ស្ថានភាពអភិវឌ្ឍន៍ក្នុងសង្កាត់បឹងត្របែក

### ៣.១.១.ស្ថានភាពសេដ្ឋកិច្ច[27]

#### ក. អាជីវកម្ម

សង្កាត់បឹងត្របែក មានមូលដ្ឋានផលិតកម្ម និងសេវាកម្មចំនួន ៣៥៥ ទីតាំង ស្មើនឹង៥៣,៥% ក្នុងនោះ រួមមានផ្នែកទំនិញ ឧបភោគបរិភោគ អាជីវកម្មហូបចុក និងអាជីវកម្មផ្សេងៗ ផលិតផល និងសេវាកម្ម ទាំងនេះ បានជួយផ្គត់ផ្គង់តម្រូវរបស់ប្រជាពលរដ្ឋក្នុង និងក្រៅមូលដ្ឋានបានយ៉ាងល្អប្រសើរ ។

#### ខ. ការងារទេសចរណ៍

អាជីវកម្ម សេវាកម្ម ក្នុងវិស័យទេសចរណ៍ មានការកើនបន្តិច ជាពិសេស ម្ចាស់អាជីវកម្មមួយចំនួន មានការយល់ដឹង និងបានពង្រឹងគុណភាពសេវាកម្ម បានផ្តល់នូវទំនុកចិត្តដល់ភ្ញៀវ ដើម្បីបានចូលក្នុងការ ប្រឡងប្រណាំង ទីក្រុងស្អាត រមណីដ្ឋានស្អាត សេវាល្អ ដែលជាផ្នែកមួយស្រូបយក ចំណូលខ្ពស់ក្នុងចំណោម ផ្នែកសំខាន់ៗទាំង៤ ។ តែក៏នៅមានទីតាំងមួយចំនួនប្រកបអាជីវកម្ម ដោយគ្មានអាជ្ញា ប័ណ្ណភាគច្រើនអាជីវកម្ម ភោជនីយដ្ឋាន គ្មានសោភ័ណភាព គ្មានចំណតយានយន្តតូច បានបង្កផលប៉ះពាល់ ដល់សណ្តាប់ធ្នាប់សាធារ ណៈយ៉ាងធ្ងន់ធ្ងរ និងមួយចំនួនទៀតមិនសូវយកចិត្តទុកដាក់លើការការពារ សន្តិសុខ សុវត្ថិភាពដល់ភ្ញៀវ និង មិនបានតក់ត្រាអត្តសញ្ញាណភ្ញៀវចេញចូល ។

#### គ. ការងារសាធារណការ

ក្នុងសង្កាត់បឹងត្របែកមានផ្លូវគមនាគមន៍ខ្វាត់ខ្វែងគ្រប់ប្រភេទ ដូចជាប្រភេទផ្លូវបេទើបកៅស៊ូ ផ្លូវចាក់ បេតុង ប្រកផ្លូវ និងស្ពានតូចៗ ព្រមទាំងមានភ្លើងបំភ្លឺតាមផ្លូវសាធារណៈដែលបង្កលក្ខណៈងាយស្រួលដល់ប្រជា ពលរដ្ឋ និងភ្ញៀវទេសចរណ៍ ក្នុងការធ្វើដំណើរដោយសុវត្ថិភាព និងប្រកបមុខរបរបានទាំងពេលថ្ងៃ និងពេលយប់ យ៉ាងងាយស្រួល ។

សមិទ្ធផលទាំងនេះកើតឡើងដោយសារថវិការបស់សាលារាជធានីភ្នំពេញ ថវិការដ្ឋបាលខណ្ឌចំការមន ថវិកាសប្បុរសជន និងថវិកាវិភាជន៍ពីរាជរដ្ឋាភិបាលតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលផ្តល់សម្រាប់ គម្រោងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ។

ទាក់ទិនទៅនឹងការងារហេដ្ឋារចនាសម្ព័ន្ធខាងលើសង្កាត់ក៏នៅមានឧបសគ្គមួយចំនួន ដូចជានៅមានផ្លូវ ទាល់ ផ្លូវតូចចង្អៀត ផ្លូវដែលបានស្ថាបនារួចហើយមានការខូចខាតទៅវិញ និងត្រូវមានការថែទាំនិងត្រូវដាក់ភ្លើ

[27] របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តន៍កម្មវិធីនយោបាយអភិវឌ្ឍន៍សង្កាត់បឹងត្របែកឆ្នាំ២០១៧-២០២១ ទំព័រទី៩

ងបំភ្លឺតាមផ្លូវសាធារណៈឲ្យបានគ្រប់ផ្លូវក្នុងភូមិទាំង៨ ។ កត្តាទាំងនេះគឺដោយសារផ្លូវខ្លះជាផ្លូវចាស់ទ្រុឌ ទ្រោម មានការសង់លំនៅដ្ឋានរំលោភលើចំណីផ្លូវ និងមានការលក់ដូរលើចិញ្ចើមផ្លូវ ។

**ឃ. ការងារកសិកម្ម**

ដោយសារតែសង្កាត់ស្ថិតនៅក្នុងតំបន់ទីប្រជុំជនកំពុងអភិវឌ្ឍន៍ ដូចនេះការងារ កសិកម្ម ហាក់ពុំមាន សកម្មភាពឡើយ ។

### ៣.១.២. ស្ថានភាពសង្គមកិច្ច[28]

**ក. ការងារអប់រំ**

នៅក្នុងសង្កាត់បឹងត្របែកមាន ៩១,៧% ក្នុងនោះសាលាបឋមសិក្សានិងមានសាលា រៀនឯកជនជាច្រើន កន្លែងទៀត ដែលបង្កលក្ខណៈងាយស្រួលដល់ការសិក្សារបស់សិស្សានុសិស្ស ឲ្យទទួល បានសេវាអប់រំ ប្រកបដោយសមធម៌ ។ អាជ្ញាធរគ្រប់លំដាប់ថ្នាក់មន្ត្រីអប់រំគ្រប់កំរិតបាន ខិតខំប្រឹងប្រែងយក អស់កំលាំងកាយ ចិត្ត ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយ (អប់រំសំរាប់ទាំងអស់គ្នា ) ឲ្យបានសំរេចប្រកប ដោយគុណភាព និងប្រសិទ្ធភាព ។ ផ្អែកតាមលទ្ធផលជាក់ស្តែងក្នុងឆ្នាំ ២០២១ បានបង្ហាញថា៖

- -កុមារក្នុងវ័យមត្តេយ្យ(៣ទៅ៥ឆ្នាំ)បានចូលរៀន ៨៩,៥% -កុមារដល់វ័យ (អាយុ៦ ឆ្នាំ) បានចូលរៀន ៩៩%
- -កុមារក្នុងវ័យបឋមសិក្សា (៦ដល់១១ឆ្នាំ) បានចូលរៀន ៩៩%
- -កុមារអាយុ ១២ ដល់១៤ឆ្នាំ បានចូលរៀន ៩៩%។

**ខ. ការងារសុខាភិបាល**

នៅក្នុងសង្កាត់បឹងត្របែកមាន ៥១,៣% ក្នុងនោះមានគ្លីនិកឯកជន ឱសថស្ថានរង បន្ទប់ពិគ្រោះព្យាបាល រួមទាំង វេជ្ជបណ្ឌិត ទន្តបណ្ឌិត គ្រូពេទ្យ ឱសថការី គិលានុបដ្ឋាក ពេទ្យឆ្មប ដៃគូអភិវឌ្ឍន៍នានា និងទទួលបាន សេវាកម្មជាតិលើកកម្ពស់សុខភាពរៀងរាល់ឆ្នាំ និងបានផ្តល់ជាប័ណ្ណមូលនិធិសមធម៌ ។

**គ. ការងារវប្បធម៌ និងសាសនា**

សង្កាត់ពុំមានវត្ត តែមានវិហារសាសនាផ្សេងៗអាចបំពេញតម្រូវការ ជូនប្រជាពលរដ្ឋគោរពប្រតិបត្តិបាន ស្រួល ។ ដោយតាមការពិនិត្យកន្លងមកឃើញថាគ្រីស្តសាសនា ច្រើនពុំមាន ការទំនាក់ទំនងជាមួយអាជ្ញាធ រមូលដ្ឋាន ធ្វើឲ្យការគ្រប់គ្រងពុំបានច្បាស់លាស់ និងច្រើនបានធ្វើអ្វីដែលច្បាប់ ហាមឃាត់ បណ្តាលឲ្យប៉ះពាល់ ដល់សោភ័ណភាពសាធារណៈ ដោយមានបិទផ្សាយគោលលិទ្ធិសាសនាតាម ដើមឈើរបងសាធារណៈ ។

**ឃ. ការងារយេនឌ័រ**

---

[28] របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តន៍កម្មវិធីនយោបាយអភិវឌ្ឍន៍សង្កាត់បឹងត្របែកឆ្នាំ២០១៧-២០២១ ទំព័រទី១០

បច្ចុប្បន្នយើងសង្កេតឃើញស្ត្រីមានតួនាទីក្នុងស្ថាប័នជាច្រើនទាំងក្នុងវិស័យ សាធារណៈ និងវិស័យឯកជន ដែលសឲ្យឃើញពីការចូលរួមយ៉ាងសកម្មរបស់ស្ត្រីក្នុងការងារសង្គម ។ ជាក់ស្តែងក្នុងសង្គមគ្រួសារក៏ដូចគ្នាដែរ ស្ត្រីមួយចំនួនបានក្លាយជាបង្គោលយ៉ាងសំខាន់ដែលមានតួនាទីទទួល ខុសត្រូវនូវកិច្ចការគ្រប់បែបយ៉ាងនៅក្នុងសង្គមគ្រួសារ ។ ទោះជាយ៉ាងនេះក្តីនៅមានគ្រួសារមួយចំនួនតូចបាន ចាត់ទុកស្ត្រីគ្រាន់តែជាមនុស្សម្នាក់ដែលអាចធ្វើបាន តែកិច្ចការផ្ទះហើយគ្រួសារមួយចំនួនទៀតបានកើតមាននូវ អំពើហឹង្សាក្នុងគ្រួសាររបស់ខ្លួនដោយសារការឈ្លោះទាស់ទែងគ្នា ដែលទទួលរងឲ្យឥទ្ធិពលនៃគ្រឿងញៀន និង គ្រឿងស្រវឹង ។

**៣.១.៣.ស្ថានភាពនៃការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងបន្សុំការប្រែប្រួលអាកាសធាតុបរិស្ថាន ៖ ដោយសារសង្កាត់ ស្ថិតនៅជាប់មាត់ប្រឡាយបង្ហូរទឹកស្អុយ ផលប៉ះពាល់អាចកើត**[29]

មានឡើងដល់បរិស្ថាន គឺការបង្ហូរកាកសំណល់ រឹង រាវ មានជាតិគីមីចូលទៅក្នុងប្រឡាយ ដែលមានជាតិពុល ពីមួយឆ្នាំទៅមួយឆ្នាំប៉ះពាល់សុខភាពប្រជាពលរដ្ឋ ដែលទាមទារការអប់រំផ្សព្វផ្សាយឲ្យបានទូលំទូលាយបន្ថែម ទៀត ជាពិសេសបញ្ហាសំរាមដែលកកស្ទះមុខលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ និងរាយប៉ាយដែលធ្វើឲ្យរថយន្តចូលមិនរួចផ្លូវ តូចចង្អៀត មិនទាន់យល់ដឹងពីវិធីញែកសំរាម នៅមានទំលាប់ចោលសំរាមផ្តេសផ្តាស ។ ម្យ៉ាងទៀតក្រុមហ៊ុន មិនបានយកចិត្តទុកដាក់ប្រមូលសំរាមឲ្យទាន់ពេលវេលាកំណត់ ។

**៣.១.៤.ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**[30]

**ក. ការគ្រប់គ្រងដែនដី**

ជារៀងរាល់ឆ្នាំ យើងតែងតែស្រង់ទិន្នន័យ ភូមិ សង្កាត់ ដើម្បីធ្វើការវិភាគ ពីស្ថានភាពរបស់មូលដ្ឋាន ។ បើទោះបីទិន្នន័យមួយចំនួនដែលទទួលបានហាក់ដូចជាមានភាពមិនទាន់ច្បាស់ លាស់ដែលតម្រូវឲ្យយើងត្រូវអនុវត្តបន្ត ព្រមទាំង សមត្ថភាពថ្នាក់ដឹកនាំភូមិ និងក្រុមប្រឹក្សាសង្កាត់ មួយចំនួននៅមានកម្រិតនៅឡើយ ដែលតម្រូវឲ្យយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីមានសមត្ថភាព គ្រប់គ្រាន់ក្នុងការបម្រើប្រជាពលរដ្ឋឲ្យមានប្រសិទ្ធិភាព។ ប៉ុន្តែសង្កាត់បានកែតម្រូវនូវចំណុចខ្វះខាតទាំងនោះហើយក៏ទទួលបានលទ្ធផលល្អប្រសើរត្រឡប់មកវិញផងដែរ។

**ខ.ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ**

ការងារសន្តិសុខក្នុងមូលដ្ឋានជារឿងចាំបាច់ដែលទាក់ទងនឹងសុវត្ថិភាពក្នុងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ អាជ្ញាធរសង្កាត់សហការជាមួយកំលាំងនគរបាលប៉ុស្ដិ៍នរដ្ឋបាល បានចុះល្បាតតាមគោលដៅ

---

[29] របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តន៍កម្មវិធីនយោបាយអភិវឌ្ឍន៍សង្កាត់បឹងត្របែកឆ្នាំ២០១៧-២០២១ ទំព័រទី១១

[30] របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តន៍កម្មវិធីនយោបាយអភិវឌ្ឍន៍សង្កាត់បឹងត្របែកឆ្នាំ២០១៧-២០២១ ទំព័រទី១២

សំខាន់ៗជារៀងរាល់ថ្ងៃ លើសពីនេះជារៀងរាល់ខែសង្កាត់បឹងត្របែកតែងតែរៀបចំវេទិកាសាធារណៈជាមួយប្រជាពល រដ្ឋក្នុងមូលដ្ឋាន ដើម្បីដោះស្រាយនូវសំណូមពរនានានិងបំពេញតម្រូវការជូនប្រជាពលរដ្ឋទាក់ទងនឹងភូមិ សង្កាត់មានប្រសិទ្ធភាពនិងសុវត្ថិភាព។

សង្កាត់បឹងត្របែកបានចុះណែនាំដល់អាជីវករទាំងអស់ឲ្យបានយល់ដឹងអំពីការថែទាំសណ្តាប់ធ្នាប់ព្រមទាំងយកទុកដាក់លើអាជីវកម្មរបស់ពួកគាត់និងមានការកែលម្អនូវរាល់ចំណុចខុសឆ្គងទាំងឡាយដូចជា ការចតយានជំនិះលើចិញ្ចើមផ្លូវ គ្មានផ្លូវសម្រាប់ធ្វើដំណើរថ្មើរជើងដែលបង្កឲ្យ មានការកកស្ទះចរាចរជាដើម។

រដ្ឋបាលរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌចំការមន ក៏ដូចជារដ្ឋបាលសង្កាត់បឹងត្របែកបានយកចិត្តទុកដាក់យ៉ាងខ្លាំងបំផុតក្នុងការដោះស្រាយបញ្ហាចិញ្ចើមផ្លូវ ដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៍ និងជៀសវាងការកើតមាន គ្រោះថ្នាក់ជាយថាហេតុ ។

## ៣.២. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឆ្នាំ២០១៨-២០២២[31]

### ៣.២.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងឆ្នាំ២០១៨

១. បានជួសជុលចាក់អ៊ិតកៅស៊ូផ្លូវលេខ ១០១ ប្រវែង១២៦ម x ៧,៥០ម នៅភូមិ៦,៨ជាគម្រោងរបស់មូលនិធិសង្កាត់ឆ្នាំ២០១៨ ។

២.បានជួសជុលដាក់ប្រព័ន្ធលូថ្មីបានចំនួន៣៥ម៉ែត្រនៅក្នុងឆ្នាំ២០១៨។

៣. ជួសជុលអណ្តូងលូនិងគម្របលូបានចំនួន៧អណ្តូង។

៤. ស្តារភក់ពីអណ្តូងលូនិងប្រព័ន្ធលូបានចំនួន១១០ម៉ែត្រ។

៥.ជួសជុលផ្លូវអ៊ិតកៅស៊ូAC

៦. ដាក់ភ្លើងបំភ្លឺផ្លូវសាធារណៈ សរុប១០កន្លែង។

៧. បានកសាងនិងសហការពង្រឹងកងកម្លាំងនគរបាលប៉ុស្តិ៍ ក្នុងនាមគណៈបញ្ជាការឯកភាពសង្កាត់ ឲ្យ ក្លាយជាកម្លាំងស្នូលពិតប្រាកដ នៃចលនាការពារភូមិ-សង្កាត់ ឲ្យមានសុវត្ថិភាព និងជាអ្នក ផ្តល់សេវាសន្តិសុខ នៅជាប់ជាមួយប្រជាជន និងឲ្យបានឆាប់រហ័សទាន់ពេលវេលានៅ ពេលមានបទ ល្មើស កើតឡើង ឬសំណូមពររបស់ប្រជាជន។

### ៣.២.២. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងឆ្នាំ២០១៩[32]

[31] របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តន៍កម្មវិធីនយោបាយអភិវឌ្ឍន៍សង្កាត់បឹងត្របែកឆ្នាំ២០១៧-២០២១ ទំព័រទី៦

[32] របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តន៍កម្មវិធីនយោបាយអភិវឌ្ឍន៍សង្កាត់បឹងត្របែកឆ្នាំ២០១៧-២០២១ ទំព័រទី៧

១. បានជួសជុលចាក់អ៊ិតកៅស៊ូផ្លូវលេខ ៤២៨ ប្រវែង១៤៣ម x ៧,៥០ម នៅក្នុងភូមិ៤,៥និងផ្លូវលេខ៤៤០ ប្រវែង ១៣៨ម x ៧,៥ក្នុងភូមិ ៦ ជាគម្រោងមូលនិធិសង្កាត់ឆ្នាំ២០១៩ ។

២. បានជួសជុលចាក់អ៊ិតកៅស៊ូផ្លូវលេខ ១០១ ប្រវែង១២៧ម x ៩ម នៅក្នុងភូមិ៦ជាគម្រោងរបស់សាលាខណ្ឌចំការ។

៣. បានអប់រំផ្សព្វផ្សាយតាមគ្រប់រូបភាពអំពីច្បាប់ចរាចរណ៍ផ្លូវគោកដើម្បីបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ។

៤.រៀបចំអនុវត្តន៍យានយន្តដើម្បីបញ្ចៀសការកកស្ទះចរាចរណ៍នៅតាមសាលារៀនតំបន់ជុំវិញផ្សារនិងទីតាំងអាជីវកម្មក្នុងសង្កាត់បឹងត្របែក។

៥. ទប់ស្កាត់អំពើអាណាចារ្យការជួញដូរមនុស្សនិងកុមារអំពើហិង្សានិងក្មេងទំនើង។

៦.សហការជាមួយស្ថាប័នពាក់ព័ន្ធនិងដៃគូនានាដើម្បីផ្សព្វផ្សាយបង្ការទប់ស្កាត់និងបង្រ្កាបការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ក្មេងទំនើង និងអំពើហិង្សាក្នុងគ្រួសារ។

៧.សហការនិងចូលរួមសកម្មភាពជួយសង្គ្រោះ កិច្ចការពារ និងស្តារនីតិសម្បទាដល់ជនងាយរងគ្រោះ។

៨. បានកសាងនិងសហការពង្រឹងកងកម្លាំងនគរបាលប៉ុស្តិ៍ ក្នុងនាមគណៈបញ្ជាការឯកភាពសង្កាត់ ឲ្យ ក្លាយជាកម្លាំងស្នូលពិតប្រាកដ នៃចលនាការពារភូមិ-សង្កាត់ ឲ្យមានសុវត្ថិភាព និងជាអ្នកផ្តល់សេវាសន្តិសុខនៅជាប់ជាមួយប្រជាជន និងឲ្យបានឆាប់រហ័សទាន់ពេលវេលានៅ ពេលមានបទ ល្មើស កើតឡើង ឬសំណូមពរ របស់ប្រជាជន។

៩. បានផ្សព្វផ្សាយពន្យល់ដល់ប្រជាពលរដ្ឋអំពីការអនុវត្តន៍ និងការទុកដាក់សំរាមកាកសំណល់រឹង រាវ ឬ វត្ថុកែច្នៃឲ្យបានត្រឹមត្រូវ។

១០. បង្កើតទំនាក់ទំនង ក៏ដូចជាណែនាំសហគ្រាសតូចធំដែលមានទីតាំងនៅក្នុងសង្កាត់អោយយល់ដឹងពីការយកចិត្តទុកដាក់ឲ្យបានល្អលើការងារនិងអាជីវកម្មរបស់ពួកគាត់ជៀសវាងបណ្តាលអោយមានការកកស្ទះលូ។

### ៣.២.៣. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងឆ្នាំ២០២០[33]

១.បានជួសជុលដាក់ប្រពន្ធ័លូរំដោះទឹកផ្លូវលេខ៤២៨ ប្រវែង២២៧ម x០,៦០មនិងផ្លូវលេខ៤២០ប្រវែង ២២៧ម x ០,៦០ម ក្នុងនៅភូមិ២ជាគម្រោងមូលនិធិសង្កាត់បឹងត្របែកឆ្នាំ២០២០ ។

[33] របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តន៍កម្មវិធីនយោបាយអភិវឌ្ឍន៍សង្កាត់បឹងត្របែកឆ្នាំ២០១៧-២០២១ ទំព័រទី៨
ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០១៨-២០២២) សង្កាត់បឹងត្របែកទំព័រទី៦០-៦១

២. បានជួសជុលចាក់អ៊ិតកៅស៊ូផ្លូវលេខ ៩៩ ប្រវែង ២១៧ម x ០,៦០មក្នុងនៅភូមិ ៦ជាគម្រោងរបស់សាលាខណ្ឌចំការមនឆ្នាំ២០២០ ។

៣. បានកសាងនិងសហការពង្រឹងកងកម្លាំងនគរបាលប៉ុស្តិ៍ ក្នុងនាមគណៈបញ្ជាការឯកភាពសង្កាត់ ឲ្យ ក្លាយជាកម្លាំងស្នូលពិតប្រាកដ នៃចលនាការពារភូមិ-សង្កាត់ ឲ្យមានសុវត្ថិភាព និងជាអ្នក ផ្តល់សេវាសន្តិសុខ នៅជាប់ជាមួយប្រជាជន និងឲ្យបានឆាប់រហ័សទាន់ពេលវេលានៅ ពេលមានបទ ល្មើស កើតឡើង ឬសំណូមពររបស់ប្រជាជន។

៤. បានជួសជុលអ៊ិតកៅស៊ូផ្លូវលេខ ៩៩ ប្រវែង ១១២០ម x ៩ម នៅភូមិ៥,៦,៧,៨ ជាគម្រោងរបស់សាលារាជធានីភ្នំពេញឆ្នាំ ២០២០ ។

៥. សហការនិងចូលរួមសកម្មភាពជួយសង្គ្រោះកិច្ចការពារនិងស្តារនីតិសម្បទាដល់ជនងាយរងគ្រោះ។

៦. បានកសាងនិងសហការពង្រឹងកងកម្លាំងនគរបាលប៉ុស្តិ៍ ក្នុងនាមគណៈបញ្ជាការឯកភាពសង្កាត់ ឲ្យ ក្លាយជាកម្លាំងស្នូលពិតប្រាកដ នៃចលនាការពារភូមិ-សង្កាត់ឲ្យមានសុវត្ថិភាព និងជាអ្នកផ្តល់សេវាសន្តិសុខនៅជាប់ជាមួយប្រជាជន និងឲ្យបានឆាប់រហ័សទាន់ពេលវេលានៅ ពេលមានបទ ល្មើស កើតឡើង ឬសំណូមពរ របស់ប្រជាជន។

៧. បានផ្សព្វផ្សាយពន្យល់ប្រជាពលរដ្ឋអំពីការអនុវត្តន៍និងចេះទុកដាក់សំរាមបានត្រឹមត្រូវ។ផ្សព្វផ្សាយជំរុញ ឱ្យមានការចូលរួម រក្សាបាននូវសុខុមាលភាពប្រជាពលរដ្ឋតាមរយៈភាពស្អាតគ្មានសំណល់ប្លាស្ទិកនៅតាមសាលារៀនឬតាមកន្លែងសាធារណៈ។

៨. ចុះផ្សព្វផ្សាយក៏ដូចជាណែនាំ ឲ្យបានជ្រួតជ្រាបដល់សហគ្រាសដែលមានទីតាំងនៅក្នុងសង្កាត់អោយមានការយកចិត្តទុកដាក់លើការប្រកបអាជីវកម្មទាំងនោះដើម្បីបញ្ចៀសការធ្វេសប្រហែលផ្សេងៗដែលអាចនាំឲ្យមានបញ្ហាកើតឡើងជាយថាហេតុ។

### ៣.២.៤. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងឆ្នាំ២០២១[34]

១. បានជួសជុលចាក់អ៊ិតកៅស៊ូផ្លូវលេខ ១០១ ប្រវែង ១៥៥ ម x ២ម នៅក្នុងភូមិ៦និងភូមិ៧ ជាគម្រោងរបស់សប្បុរសជនឆ្នាំ២០២១ ។

២. បានជួសជុលដាក់ប្រពន្ធ័លូរំដោះទឹកផ្លូវលេខ៩៥ប្រវែង ២៨៦ម x ០,៦០ម នៅភូមិ៥,៦ ជាគម្រោងមូនិធិភូមិសង្កាត់ឆ្នាំ២០២១ ។

[34] របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តន៍កម្មវិធីនយោបាយអភិវឌ្ឍន៍សង្កាត់បឹងត្របែកឆ្នាំ២០១៧-២០២១ ទំព័រទី៩

៣. បានកសាងនិងសហការពង្រឹងកងកម្លាំងនគរបាលប៉ុស្តិ៍ ក្នុងនាមគណៈបញ្ជាការឯកភាពសង្កាត់ ឲ្យក្លាយជាកម្លាំងស្នូលពិតប្រាកដនៃចលនាការពារភូមិ-សង្កាត់ឲ្យមានសុវត្ថិភាពប្រសិទ្ធភាព និងជាអ្នកផ្តល់សេវាសន្តិសុខជាមួយប្រជាជន និងឲ្យបានឆាប់រហ័សទាន់ពេលវេលានៅ ពេលមានបទ ល្មើស កើតឡើង ឬសំណូមពរនិងសំណើររបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ។

៤.បានផ្សព្វផ្សាយពន្យល់ប្រជាពលរដ្ឋអំពីការអនុវត្តន៍និងចេះទុកដាក់សំរាមបានត្រឹមត្រូវ។ ផ្សព្វផ្សាយជំរុញឱ្យមានការចូលរួមរក្សាបាននូវសុខុមាលភាពប្រជាពលរដ្ឋតាមរយៈភាពស្អាតអនាម័យគ្មានសំណល់ប្លាស្ទិក នៅតាមសាលារៀនឬតាមកន្លែងសាធារណៈ។ ដោយភ្ជាប់បន្ថែមប្រជាពលរដ្ឋខ្លួនឯងត្រូវមានការចាប់ផ្តើមចេះសម្អាតអនាម័យ ប្រមូលវេចខ្ចប់ទុកដាក់រួមទាំងការញែកសំរាមនិងចូលរួមក្នុងយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក កាន់តែច្រើន និងផុសផុលឡើង។

៥.ពង្រីកគម្រោងសេវាទឹកស្អាតការចុះដាក់ថ្នាំអាបែតក្នុងពាងទឹកតាមផ្ទះចំនួន១០ទីតាំងក្នុងឆ្នាំ២០២១។

៦.មានការផ្សព្វផ្សាយព័ត៌មានយ៉ាងទូលំទូលាយដែលទាក់ទងនឹងសុខភាព ព្រមទាំងផ្តល់ការចាក់វ៉ាក់សាំងដល់ស្រ្តីនិងកុមារនៅក្នុងសង្កាត់បឹងត្របែក និងទទួលយកសំណូមពរនិងដោះស្រាយចំពោះបញ្ហារបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

### ៣.២.៥. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងឆ្នាំ២០២២

១.ដាក់ប្រព័ន្ធលូរំដោះទឹកមូលផ្លូវលេខ១០១ប្រវែង៤០២x០,៦០មដែលស្ថិតនៅក្នុងភូមិ៦ និងភូមិ៧។

២. មានការផ្សព្វផ្សាយព័ត៌មានយ៉ាងទូលំទូលាយដែលទាក់ទងនឹងសុខភាព ព្រមទាំងផ្តល់ការចាក់វ៉ាក់សាំងដល់ស្រ្តីនិងកុមារនៅក្នុងសង្កាត់បឹងត្របែក។

៣.ផ្តល់សេវាកម្មពិគ្រោះ ដល់ស្រ្តីមានផ្ទៃពោះរួមទាំង ការអប់រំចំណេះដឹងពីសុខភាព។

៤.បានចុះអប់រំក៏ដូចជាផ្សព្វផ្សាយអំពីច្បាប់ទេសចរណ៍បណ្តុះបណ្តាលបដិសណ្ឋារកិច្ចនិងចលនាប្រណាំងប្រជែងទីក្រុងស្អាតរម្មណីដ្ឋានស្អាតសេវាល្អបាន១វគ្គគាំទ្រដោយយេ។

៥.ពង្រីកគម្រោងសេវាទឹកស្អាតការចុះដាក់ថ្នាំអាបែតក្នុងពាងទឹកតាមផ្ទះចំនួន១០ទីតាំងក្នុងឆ្នាំ២០២២។

៦.បានចុះកំណត់អត្តសញ្ញាណកម្មប្រជាជនក្រីក្រដើម្បីផ្តល់ប័ណ្ណមូលនិធិសមធម៌ចំនួន១៥០គ្រួសារត្រូវបានគាំទ្រដោយមន្ទីរសង្គមកិច្ច។

៧.ផ្តល់កូនឈើនិងដាំកូនឈើចំនួន២០០ដើមនៅក្នុងឆ្នាំ២០២២ដោយប្រភពគាំទ្រគឺរដ្ឋបាលព្រៃឈើ។

៨.ពង្រឹងសមត្ថភាពនគរបាលប៉ុស្តិ៍រដ្ឋបាលចំនួន២លើកគាំទ្រដោយសាលាខណ្ឌចំការមន។

៩.ពង្រឹងការត្រួតពិនិត្យនិងបង្ក្រាបល្បែងហ្គេមអ៊ីនធឺណេត និងវីឌីអូរអាសអាភាសចំនួន២លើកគាំទ្រដោយមន្ទីរវប្បធម៌។

១០.អប់រំចំណេះដឹងគ្រឿងញៀន និងច្បាប់ពាក់ព័ន្ធចំនួន១វគ្គគាំទ្រដោយសាលាខណ្ឌចំការមន។

១១.ការជួយគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ចំនួន១២លើកប្រភពគាំទ្រគឺមន្ទីរសុខាភិបាល។

១២.គាំទ្រកុមារកំព្រាដោយសារជំងឺអេដស៍ចំនួន១២លើក ។

១៣.បានចុះណែនាំនិងជំរុញឳពុកម្តាយអោយនាំកូនចូលរៀនអោយបានគ្រប់ៗគ្នាចំនួន១វគ្គគាំទ្រដោយមន្ទីរអប់រំ។

១៤. ពង្រឹងកិច្ចការចុះបញ្ជីអត្រានុកូលដ្ឋានចំនួន១វគ្គគាំទ្រដោយសាលាខណ្ឌចំការមន។

# ជំពូកទី៤

# ការវិភាគទិន្នន័យនៃការអភិវឌ្ឍផ្លូវ
# និងប្រព័ន្ធលូដែលសង្កាត់បឹងត្របែក
# បានសម្រេចបានពីឆ្នាំ២០១៨ដល់
# ២០២២

# ជំពូកទី៤

# ការវិភាគទិន្នន័យនៃការអភិវឌ្ឍផ្លូវនិងប្រព័ន្ធលូដែលសង្កាត់បឹងត្របែកបានសម្រេចបានពីឆ្នាំ២០១៨ដល់២០២២

## ៤.១.ទិន្នន័យផ្លូវដែលសង្កាត់បឹងត្របែកសម្រេចបានពីឆ្នាំ២០១៨ដល់២០២២[35]

សង្កាត់បឹងត្របែកបានខិតខំប្រឹងប្រែងក្នុងការពង្រីកវិសាលភាពនឹងទំហំ ក្នុងការអភិវឌ្ឍទៅលើការជួសជុលផ្លូវអ៊ុតកៅស៊ូពីមួយឆ្នាំទៅមួយឆ្នាំព្រោះថាបច្ចុប្បន្ននេះប្រជាពលរដ្ឋក្នុងមូលដ្ឋាន មានការជួបប្រទះនូវផលលំបាកក្នុងការធ្វើដំណើរទៅមក និងធ្វើការប្រកបរបរអាជីវកម្មនានារបស់ប្រជាពលរដ្ឋផ្ទាល់ដែលអាចឲ្យមានការខាតបង់។ ក្នុងនោះផងដែរ សង្កាត់បឹងត្របែកបានជួយសម្រួលក្នុងការអភិវឌ្ឍជួសជុលផ្លូវក្នុងសង្កាត់ដើម្បីឲ្យមានភាពងាយស្រួលដល់ប្រជាជនក្នុងការធ្វើដំណើរដោយសុវត្ថិភាព និងប្រជាពលរដ្ឋដែលធ្វើអាជីវកម្ម ដែលនៅក្បែរផ្លូវក្នុងមូលដ្ឋានដោយមិនមានការប៉ះពាល់ឬខាតបង់ដល់មុខរបរ របស់ពួកគាត់។ ប្រវែងផ្លូវដែលសង្កាត់បឹងត្របែកបានធ្វើការអភិវឌ្ឍជួសជុលឆ្នាំ២០១៨ ផ្លូវលេខ១០១ មានប្រវែង១២៦ម៉ែត្រ ឆ្នាំ២០១៩ ផ្លូវលេខ៤២៦ ប្រវែង១៤៣ម៉ែត្រ ឆ្នាំ២០២០ ផ្លូវលេខ៩៩ មានប្រវែង ១២៧ម៉ែត្រ ចំណែកឯឆ្នាំ២០២១ ផ្លូវលេខ ១០១មានប្រវែង ១៥៥ម៉ែត្រ និងក្នុងឆ្នាំ២០២២ ផ្លូវលេខ៤៣២-៤៣៦ មានប្រវែង១០៩ម៉ែត្រ។

### ៤.១.១.តារាងទិន្នន័យផ្លូវចាក់កៅស៊ូដែលសម្រេចបានឆ្នាំ២០១៨ដល់២០២២

តារាងខាងក្រោមនេះបង្ហាញពីការជួសជុលផ្លូវចាក់អ៊ុតកៅស៊ូACនៅក្នុងសង្កាត់បឹងត្របែកដែលបានសម្រេចបានចាប់ពីឆ្នាំ២០១៨-២០២២។

**តារាងទី ៤.១.១៖** ប្រវែងជួសជុលផ្លូវអ៊ុតកៅស៊ូACឆ្នាំ២០១៨-២០២២

| ឆ្នាំ | ផ្លូវលេខ | ប្រវែងគិតជាម៉ែត្រ(ប្រវែងបណ្តោយ) |
|---|---|---|
| ២០១៨ | ១០១ | ១២៦ម |
| ២០១៩ | ៤២៨ | ១៤៣ម |
| ២០២០ | ៩៩ | ១២៧ម |
| ២០២១ | ១០១ | ១៥៥ម |
| ២០២២ | ៤៣២-៤៣៦ | ១០៩ម |

(ឧបសម្ព័ន្ធទី៤៖របាយការណ៍លទ្ធផលសម្រេចបានក្នុងការជួសជុលផ្លូវអ៊ុតកៅស៊ូACឆ្នាំ២០១៨-២០២២របស់សង្កាត់បឹងត្របែក)។

[35] របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តន៍កម្មវិធីនយោបាយអភិវឌ្ឍន៍សង្កាត់បឹងត្របែកឆ្នាំ២០១៧-២០២១ ទំព័រទី៦

### ៤.១.២.ក្រាហ្វិកផ្លូវចាក់កៅស៊ូដែលសម្រេចបានពីឆ្នាំ២០១៨ដល់២០២២

ក្រាហ្វិកទី៤.១.២៖បង្ហាញពីការសម្រេចបានក្នុងការជួសជុលចាក់អ៊ិតកៅស៊ូACនៅឆ្នាំ(២០១៨-២០២២)គិតជាម៉ែត្រ៖




### ៤.១.៣.ការវិភាគនិងបកស្រាយទិន្នន័យផ្លូវចាក់កៅស៊ូតាមក្រាហ្វិកដែលសង្កាត់បឹងត្របែកបានជួសជុលឆ្នាំ២០១៨ដល់២០២២[36]

ការវិភាគតាមក្រាហ្វិកខាងលើនេះបានបង្ហាញអោយឃើញពីប្រវែងនៃការជួសជុលផ្លូវចាក់អ៊ិតកៅស៊ូAC និងកំណើននៃបរិមាណតាមឆ្នាំនីមួយដែលបានជួសជុលតាមផ្លូវលេខនិងក្នុងភូមិនីមួយៗរបស់សង្កាត់បឹងត្របែកចាប់ពីឆ្នាំ២០១៨-២០២២ មានដូចខាងក្រោម៖

- ឆ្នាំ២០១៨ បានជួសជុលចាក់អ៊ិតកៅស៊ូផ្លូវលេខ១០១ប្រវែង១២៦ម៉ែត្រនៅភូមិ៦និង ភូមិ៨ជាគម្រោងរបស់មូលនិធិសង្កាត់បើគិតជាភាគរយគឺស្មើរនិង១១.៨៩%។
- ឆ្នាំ២០១៩បានជួសជុលចាក់អ៊ិតកៅស៊ូផ្លូវលេខ ៤២៨ ប្រវែង១៤៣ម៉ែត្រនៅក្នុងភូមិ៤,៥ នៅឆ្នាំ២០១៩ជា

[36] របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តន៍កម្មវិធីនយោបាយអភិវឌ្ឍន៍សង្កាត់បឹងត្របែកឆ្នាំ២០១៧-២០២១ ទំព័រទី៦

• គម្រោងមូលនិធិសង្កាត់បើប្រៀបធៀបជាភាគរយរវាងឆ្នាំ(២០១៨-២០១៩)គឺនៅឆ្នាំ២០១៩ស្មើរ១៣,៤៩% បើធៀបជាមួយ២០១៨មានការកើនឡើង១,៦%។

• ២០២០បានជួសជុលចាក់អ៊ុតកៅស៊ូផ្លូវលេខ ៩៩ ប្រវែង២១៧ម៉ែត្រនៅភូមិ៦ជាគម្រោងរបស់សាលាខណ្ឌចំការមនបើជាប្រៀបធៀបជាភាគរយរវាងឆ្នាំ(២០១៩-២០២០)គឺឆ្នាំ២០២០ស្មើរនិង១១,១៩%បើធៀបជាមួយឆ្នាំ២០១៩នោះឆ្នាំ២០២០មានការធ្លាក់ចុះ២.៣%។

• ឆ្នាំ២០២១ បានជួសជុលចាក់អ៊ុតកៅស៊ូផ្លូវលេខ ១០១ បានប្រវែង ១៥៥ម៉ែត្រនៅក្នុងភូមិ៦ ជាគម្រោងរបស់សប្បុសជន បើជាប្រៀបធៀបជាភាគរយរវាងឆ្នាំ(២០២០-២០២១)គឺឆ្នាំ២០២១ស្មើរនិង២២.០៥%បើធៀបជាមួយឆ្នាំ២០២០នោះឆ្នាំ២០២១មានការកើនឡើងចំនួន១០.៨៦%។

• នៅឆ្នាំ២០២២បានជួសជុលចាក់អ៊ុតកៅស៊ូផ្លូវលេខ ៤៣២-៤៣៦បានប្រវែង១០៩ម៉ែត្រគម្រោងរបស់សាលាខណ្ឌចំការមន បើជាប្រៀបធៀបជាភាគរយរវាងឆ្នាំ(២០២១-២០២២)គឺឆ្នា២០២២ការជួសជុលថយចុះស្មើរនិង២៩.៦៧%។

